**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**នាយកដ្ឋាន ឱសថ ចំណីអាហារ បរិក្ខារពេទ្យ**
**និងគ្រឿងសំអាង**

# គោលការណ៍អនុវត្តល្អក្នុងការរៀបចំ ទុកដាក់ឱសថនិងផលិតផលសុខាភិបាល

ខែ ធ្នូ ឆ្នាំ២០១៥

ឧបត្ថម្ភដោយ អង្គការសុខភាពពិភពលោក

## អារម្ភកថា

ការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលជាការងារមួយចាំបាច់ និងសំខាន់បំផុតក្នុងការគ្រប់គ្រងឱសថ និងផលិតផលសុខាភិបាល នៅតាមឃ្លាំងឱសថ ឱសថស្ថាន ទាំងផ្នែកសេវាសាធារណៈ និង សេវាឯកជន។ ការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល ពុំបានត្រឹមត្រូវបណ្តាលឲ្យមាន ឱសថ កកស្ទះ ឱសថដាច់ស្តុក ឱសថខូចគុណភាព និងឱសថហួសកាលបរិច្ឆេទប្រើនៅលើធ្នើរ ដែលជាហេតុធ្វើឲ្យខាតបង់នូវថវិកាដោយការធ្វេសប្រហែសនេះ។ ដើម្បីកាត់បន្ថយបញ្ហាខាងលើឲ្យមាននៅតិចបំផុតនោះ ការិយាល័យឱសថសារវន្តនៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ក្រសួងសុខាភិបាល ដោយមានការឧបត្ថម្ភបច្ចេកទេសពីអង្គការសុខភាពពិភពលោក បានរៀបចំចងក្រងនូវគោលការណ៍អនុវត្តល្អក្នុងការរៀបចំទុកដាក់ឱសថ សម្រាប់ចែកជូនដល់ឱសថការី ឬអ្នកទទួលខុសត្រូវឃ្លាំងឱសថ ឬមន្ត្រីឃ្លាំងឱសថ ឬម្ចាស់ឱសថស្ថាន ឱសថស្ថានរង ក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងសេវាសាធារណៈនិងសេវាឯកជន យកទៅអនុវត្តក្នុងការប្រកបការងារប្រចាំថ្ងៃ។

គោលការណ៍អនុវត្តល្អក្នុងការរៀបចំទុកដាក់ឱសថ ត្រូវរៀបចំឡើងជា ៦ផ្នែកធំៗ៖

១- ការទទួល និងរៀបចំឱសថ និងផលិតផលសុខាភិបាល

២- ការរក្សាទុកឯកសារគ្រប់គ្រងឱសថ និងផលិតផលសុខាភិបាលនៅក្នុងឃ្លាំង

៣- លក្ខខណ្ឌពិសេសនៃការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល

៤- ការរក្សាគុណភាពឱសថ និងផលិតផលសុខាភិបាល

៥- ការធានាសន្តិសុខ និងសុវត្ថិភាព

៦- ឧបសម្ព័ន្ធ៖ ឧបសម្ព័ន្ធ ១( ការរក្សាទុកដាក់ និងលក្ខខណ្ឌស្លាកសញ្ញា) ឧបសម្ព័ន្ធ ២( តារាងវាយតម្លៃ ដើម្បីអនុវត្តស្វ័យត្រួតពិនិត្យ) និងឧបសម្ព័ន្ធ៣ (គំរូរបាយការណ៍ស្តីពីឱសថនិង ផលិតផលសុខាភិបាលខូចគុណភាព) ។

ក្រសួងសុខាភិបាលសង្ឃឹម និងជឿជាក់ថាតាមរយៈឯកសារនេះ ឱសថការី ឬអ្នកទទួលខុសត្រូវឃ្លាំងឱសថ ឬមន្ត្រីឃ្លាំងឱសថ ឬម្ចាស់ឱសថស្ថាន ឱសថស្ថានរងទាំងអស់ មានការយល់ដឹងអំពីភារៈកិច្ចរបស់ខ្លួន ក្នុងការរក្សាទុកដាក់ឱសថ ធ្វើយ៉ាងណាឲ្យឱសថប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព សម្រាប់ចែកចាយយកទៅព្យាបាលជូនប្រជាជន តាមសេវាសាធារណៈក៏ដូចជាសេវាឯកជន ។ ម្យ៉ាងទៀតឯកសារនេះក៏ជាមូលដ្ឋានរួមចំណែក ក្នុងការកាត់បន្ថយការចំណាយខ្ជះខ្ជាយ ក្នុងការផ្គត់ផ្គង់ឱសថ និងផលិតផលសុខាភិបាល ។

រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ ៨ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

# សេចក្តីថ្លែងអំណរគុណ

នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ឯកឧត្តម ជូ យិន ស៊ីម រដ្ឋលេខាធិការក្រសួងសុខាភិបាល
- លោកជំទាវ ឱ វណ្ណឌីន អគ្គនាយកបច្ចេកទេសសុខាភិបាល

ដែលបានគាំទ្រនិងជំរុញការអនុវត្តន៍គោលការណ៍អនុវត្តល្អក្នុងការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល សម្រាប់សេវាសុខាភិបាលទាំងអស់។

- លោកឱសថបណ្ឌិត ហេង ប៊ុនគៀត ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ និងគ្រឿងសំអាង ដែលបានជំរុញការងារផ្តល់យោបល់ កែលំអខ្លឹមសារឯកសារ គោលការណ៍អនុវត្តល្អក្នុងការរៀបចំទុកដាក់ឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលនេះ។

- លោក លោកស្រីដែលជាថ្នាក់ដឹកនាំនាយកដ្ឋាន ថ្នាក់ដឹកនាំការិយាល័យ និងមន្ត្រី នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង លោកប្រធានឃ្លាំងឱសថកណ្តាល ប្រធានការិយាល័យឱសថខេត្ត ប្រធានឃ្លាំងឱសថស្រុកប្រតិបត្តិ និងប្រធានឃ្លាំងឱសថមណ្ឌលសុខភាព ព្រមទាំងតំណាងក្រុមហ៊ុនឱសថ និងឱសថស្ថាន ដែលបានចូលរួមផ្តល់មតិ និងបទពិសោធន៍ល្អៗ ធ្វើឲ្យឯកសារគោលការណ៍អនុវត្តល្អក្នុងការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលនេះ កាន់តែមានភាពសុក្រិត្យ និងអាចអនុវត្តបាន។

- លោកឱសថបណ្ឌិត យ៉ង់ ដារារុធ និង លោកស្រីឱសថបណ្ឌិត ឱ ឧត្តមរដ្ឋ ដែលបានរៀបចំនិងចងក្រងឯកសារគោលការណ៍អនុវត្តល្អ ក្នុងការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលនេះ និង សូមថ្លែងអំណរគុណផងដែរចំពោះលោកស្រី LKHAGVADORJ VANCHINSUREN ទីប្រឹក្សាអង្គការសុខភាពពិភពលោក ដែលបានជួយកែសម្រួលបន្ថែមឯកសារនេះ ឲ្យបានកាន់តែល្អប្រសើរឡើង។

នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង សូមថ្លែងអំណរគុណផងដែរចំពោះការជួយឧបត្ថម្ភ របស់អង្គការសុខភាពពិភពលោក ក្នុងការរៀបចំនិងបោះពុម្ពនូវគោលការណ៍ណែនាំនេះ។

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........ ៣
សេចក្តីផ្តើម ........ ៥
គម្រូវការទូទៅ ........ ៦
**ការងារគ្រប់គ្រងឃ្លាំងឱសថនិងផលិតផលសុខាភិបាល** ........ ៧
**១.ការទទួលនិងការរៀបចំឱសថនិងផលិតផលសុខាភិបាល** ........ ៨
    ១.១. ការទទួលឱសថនិងផលិតផលសុខាភិបាល ........ ៨
    ១.២. ការរៀបចំឱសថនិងផលិតផលសុខាភិបាល ........ ១០
    ១.៣. ការបង្វិលស្តុកឱសថនិងផលិតផលសុខាភិបាល ........ ១០
    ១.៤. ការរៀបចំឱសថនិងផលិតផលសុខាភិបាល ........ ១១
**២.ការរក្សាឯកសារគ្រប់គ្រងឱសថនិងផលិតផលសុខាភិបាលនៅក្នុងឃ្លាំង** ........ ១១
    ២.១. បញ្ជីស្តង់ដារមុខឱសថនិងផលិតផលសុខាភិបាល ........ ១១
    ២.២. សលាកបត្រឃ្លាំង ........ ១២
    ២.៣. ការធ្វើសារពើភ័ណ្ឌដោយដៃ ........ ១៣
**៣. លក្ខខណ្ឌពិសេសនៃការរៀបចំទុកដាក់ឱសថនិងផលិតផលសុខាភិបាល** ........ ១៥
    ៣.១. ឧទាហរណ៍នៃការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល ដែលអាចឲ្យត្រួតពិនិត្យបាន ........ ១៥
    ៣.២. ឧបករណ៍និងសម្ភារៈសម្រាប់រៀបចំទុកដាក់ឱសថនិងផលិតផលសុខាភិបាល ........ ១៦
    ៣.៣.សារធាតុងាយឆេះ ........ ១៧
    ៣.៤. សារធាតុកាត់ ........ ១៧
**៤. ការរក្សាគុណភាពឱសថនិងផលិតផលសុខាភិបាល** ........ ១៨
    ៤.១ ការត្រួតពិនិត្យគុណភាពឱសថនិងផលិតផលសុខាភិបាល ........ ១៨
    ៤.២. ឱសថ និងផលិតផលដែលបញ្ជូនត្រឡប់វិញនិងការប្រមូលមកវិញ ........ ១៩
    ៤.៣. ការត្រួតពិនិត្យសីតុណ្ហភាព ........ ១៩
    ៤.៤. បង្ការការខូចគុណភាពនិងការចម្លងសារធាតុផ្សេងៗ ........ ២២
    ៤.៥. ការការពារសត្វចង្រៃ ........ ២៣
**៥. ការធានាសន្តិសុខនិងសុវត្ថិភាព** ........ ២៤
    ៥.១. ការពារអគ្គីភ័យ ........ ២៤
    ៥.២. ការពារការបាត់បង់ ........ ២៥
**៦. ឧបសម្ព័ន្ធ** ........ ២៦
    ឧបសម្ព័ន្ធ ១ ៖ ការរក្សាទុកដាក់ និងលក្ខណ្ឌស្លាកសញ្ញា ........ ២៦
    ឧបសម្ព័ន្ធ ២ ៖ តារាងវាយតម្លៃ ដើម្បីអនុវត្តស្វ័យត្រួតពិនិត្យ ........ ២៧
    ឧបសម្ព័ន្ធ ៣ ៖ គំរូកំណត់ហេតុស្តីពីឱសថនិងផលិតផលសុខាភិបាលខូចគុណភាព ........ ៣១

# សេចក្ដីផ្ដើម

ការរៀបចំទុកដាក់គឺជាសកម្មភាពមួយដ៏សំខាន់ ក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ឱសថ ។ ឱសថសង្គ្រោះជីវិត និងធ្វើឲ្យសុខភាពប្រសើរឡើង បើសិនជាមានឱសថប្រើប្រាស់គ្រប់គ្រាន់ ប្រកបដោយគុណភាពល្អ និងប្រើប្រាស់បានត្រឹមត្រូវ ។ គោលបំណងនៃគោលការណ៍អនុវត្តន៍ល្អ ក្នុងការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល គឺធានាឲ្យប្រាកដថាការផ្គត់ផ្គង់ឱសថមានគុណភាពល្អ រៀបចំទុកដាក់ក្នុងឃ្លាំងបានត្រឹមត្រូវ គ្រប់គ្រងដោយបុគ្គលិកដែលបានទទួលការបណ្ដុះបណ្ដាលរួច និងមានឱសថគ្រប់គ្រាន់សម្រាប់ បម្រើសេចក្ដីត្រូវការរបស់ប្រជាជនកម្ពុជា។

គោលការណ៍អនុវត្តន៍ល្អក្នុងការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលជួយធានាឲ្យផលិតផលឱសថមានគុណភាព សុវត្ថិភាពដូចគ្នានៅក្នុងវដ្ដនៃការផ្គត់ផ្គង់រហូតដល់ដៃអ្នកប្រើប្រាស់។ ការ រៀបចំទុកដាក់ឱសថដោយពុំបានត្រឹមត្រូវ បណ្ដាលឲ្យមានការភាន់ច្រឡំកន្លែងទុកដាក់ មានឱសថហួសកំណត់ពេលប្រើ មានឱសថដាច់ស្តុក និងលើសស្តុក ព្រមទាំងធ្វើឲ្យខូចគុណភាពឱសថ បង្កឲ្យមាន បញ្ហាដល់ សុខភាព ដូចជាការព្យាបាល ពុំបានជាប់លាប់ ការស៊ាំនឹងឱសថប្រឆាំងមេរោគ ក៏ដូចគ្នានឹងការ ខ្ជះខ្ជាយនូវ ប្រភពថវិកា។ ការរៀបចំទុកដាក់ជាគន្លឹះមួយនៅក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាល វិស័យឱសថ ២០១៣-២០១៨ និងគោលនយោបាយស្ដីពីឱសថឆ្នាំ ២០១០ របស់ព្រះរាជាណាចក្រកម្ពុជា។

គោលការណ៍នេះពុំមែនសម្រាប់តែអនុវត្តនៅតាមសេវាសាធារណៈ ដូចជាឃ្លាំងឱសថកណ្ដាល ឃ្លាំងឱសថស្រុកប្រតិបត្តិ ឱសថស្ថានមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យស្រុកប្រតិបត្តិប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់យកទៅប្រើប្រាស់នៅតាមសេវាឯកជន ដូចជាឃ្លាំងឱសថគ្រឹះស្ថាន អាហារណ៍នីហារណៃឱសថ ឱសថស្ថាន និងឱសថស្ថានរង។

គោលការណ៍អនុវត្តល្អក្នុងការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល ជាគោលការណ៍មួយដែលបានរៀបចំឡើង ដោយការិយាល័យឱសថសារវន្តនៃនាយកដ្ឋានឱសថ ចំណីអាហារបរិក្ខារពេទ្យ និងគ្រឿងសំអាង ក្រសួងសុខាភិបាល សម្រាប់ជាមគ្គុទ្ទេសក៍ ចំពោះឱសថការីនិងបុគ្គលិកសុខាភិបាល ដើម្បីការពារសុខភាពសាធារណៈ និងធានាឲ្យបាននូវការអនុវត្តន៍ល្អក្នុងការគ្រប់គ្រងឱសថ។

## តម្រូវការទូទៅ

- បុគ្គលិកទាំងអស់ត្រូវទទួលការបណ្តុះបណ្តាលដ៏ត្រឹមត្រូវ ទាក់ទងជាមួយនឹងការអនុវត្តល្អ ក្នុងការរៀបចំទុកដាក់ឱសថ ការងារនិយ័តកម្ម នីតិវិធីផ្សេងៗ និងសុវត្ថិភាព។
- បុគ្គលិកដែលធ្វើការនៅឃ្លាំងឱសថ ត្រូវប្រើសម្លៀកបំពាក់សម្រាប់ការពារ ក្នុងពេលបំពេញការងារ ឲ្យត្រូវនឹងសកម្មភាពដែលត្រូវអនុវត្ត។
- ត្រូវមានតួនាទី និងភារកិច្ចរបស់បុគ្គលិកនីមួយៗដែលពាក់ព័ន្ធ ជាលាយលក្ខណ៍អក្សរ និងកត់ត្រាទុក។ សកម្មភាពមួយចំនួនតម្រូវឲ្យមានការយកចិត្តទុកដាក់ឲ្យបានខ្លាំង ដូចជាការតាមដានក្នុងការអនុវត្តសកម្មភាព ឲ្យឆ្លើយតបទៅនឹងគោលការណ៍ណែនាំ។
- ឃ្លាំងឱសថត្រូវរៀបចំយ៉ាងណា ធានាឲ្យបាននូវលក្ខខណ្ឌល្អក្នុងការទុកដាក់ឱសថ ជាពិសេសត្រូវតែស្អាត ស្ងួត និងរក្សាសីតុណ្ហភាពក្នុងការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល ដែលមាននៅលើស្លាកសញ្ញារបស់វា (ឧ. សីតុណ្ហភាពសំណើមដែលមានការប្រែប្រួល ) ត្រូវធ្វើការពិនិត្យតាមដាននិងកត់ត្រា។ ត្រូវរក្សាទុកឱសថនិងផលិតផលសុខាភិបាល ឲ្យផុតពីកំរាលឥដ្ឋ ធ្វើយ៉ាងណាឲ្យមានចន្លោះអាចបោសសម្អាត និងធ្វើការត្រួតពិនិត្យបាន។
- ឃ្លាំងឱសថត្រូវមានទំហំធំសមស្របដែលអាចស្តុកឱសថ និងផលិតផលសុខាភិបាលមិនឲ្យលើសពីចំណុះ ៦០% នៃចំណុះឃ្លាំង។
- ត្រូវកំណត់ និងធ្វើការត្រួតពិនិត្យនូវឱសថ និងផលិតផលសុខាភិបាលដែលពុំអាចទទួលយកបាន ហើយរក្សាទុកនៅកន្លែងដាច់ដោយឡែក (Quarantine) រហូតដល់មានការសម្រេចទទួលយកឱសថ និងផលិតផលសុខាភិបាលទាំងនោះ។
- ត្រូវដកចេញ ឬទុកដោយឡែកនូវឱសថ និងផលិតផលសុខាភិបាលដែលបែកបាក់និងខូចគុណភាព។
- ត្រូវធ្វើយ៉ាងណារក្សាឲ្យបានត្រឹមត្រូវ នូវគុណភាពឱសថ និងផលិតផលសុខាភិបាល ទៅតាមលក្ខខណ្ឌ នៃការរៀបចំទុកដាក់ពេលដឹកជញ្ជូនតាមផ្លូវ។
- ប្រធានឃ្លាំងឬអ្នកទទួលខុសត្រូវឃ្លាំងឱសថ ត្រូវធ្វើស្វ័យត្រួតពិនិត្យជាប្រចាំដោយប្រើតារាងត្រួតពិនិត្យ (Check List) (ឧបសម្ព័ន្ធ២) ដើម្បីធានាថាតម្រូវការទាំងអស់ ត្រូវបានអនុវត្តកាន់តែប្រសើរឡើង។

## ការងារគ្រប់គ្រងឃ្លាំងឱសថ និងផលិតផលសុខាភិបាល

ការងារប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ ៖

- ត្រួតពិនិត្យលក្ខខណ្ឌនៃការរៀបចំទុកដាក់ឱសថនិងផលិតផលសុខាភិបាល
- កត់ត្រាសីតុណ្ហភាព និងសំណើម
- សម្អាតកន្លែងទទួល រៀបចំទុកដាក់ វេចខ្ចប់ និងបញ្ជូនចេញ
- បោស ឬជូតកំរាលឥដ្ឋ
- ប្រមូលសម្រាមចេញរាល់ថ្ងៃ
- សម្អាតធុងសម្រាម ធ្នើរ និងទូបើសិនចាំបាច់
- ធានាមានច្រកចេញចូលក្នុងឃ្លាំងឲ្យទូលាយ និងស្អាត
- ធានាឲ្យមានខ្យល់ចេញចូលគ្រប់គ្រាន់ និងត្រជាក់
- ធានាកុំឲ្យឱសថនិងផលិតផលសុខាភិបាលប៉ះផ្ទាល់នឹងពន្លឺថ្ងៃ
- ត្រួតពិនិត្យសន្តិសុខ និងសុវត្ថិភាពឃ្លាំង
- ពិនិត្យមើលការលេចឬជ្រាបនៃដំបូលឃ្លាំង ពិសេសនៅរដូវភ្លៀង អំឡុងពេល និងបន្ទាប់ពីមានព្យុះ
- ត្រួតពិនិត្យគុណភាពឱសថ និងផលិតផលសុខាភិបាល (ពិនិត្យមើលដោយផ្ទាល់ និងពិនិត្យថ្ងៃ ខែឆ្នាំផុតកំណត់ប្រើប្រាស់)
- ធានាទុកដាក់ឱសថនិងផលិតផលសុខាភិបាលឲ្យបានត្រឹមត្រូវ (តើកេសខាងក្រោមដែលគេគរពីលើអាចបែកបាក់ដែរឬទេ?)
- ធ្វើបច្ចុប្បន្នភាពលើកំណត់ត្រាស្តុកនិងរក្សាសំណុំឯកសារ
- ពេលធ្វើសារពើភ័ណ្ឌតាមវដ្ត (cycle counting) ត្រូវធ្វើការរាប់ដោយដៃនិងធ្វើបច្ចុប្បន្នភាពបញ្ជីស្តុក
- ត្រួតពិនិត្យកម្រិត បរិមាណ និងសុវត្ថិភាពស្តុក
- ស្នើសុំបន្ទាន់ឬបញ្ជាទិញ (នៅពេលចាំបាច់ដោយអនុវត្តតាមគោលការណ៍ណែនាំ)
- ធ្វើបច្ចុប្បន្នភាពសំណុំឯកសារត្រួតពិនិត្យសារពើភ័ណ្ឌដោយកុំព្យូទ័រ
- ធ្វើបច្ចុប្បន្នភាពសលាកបត្រឃ្លាំងព្យួរ (លើធ្នើរក្នុងឃ្លាំងត្រង់ឱសថនីមួយៗ)
- ដកចេញនូវឱសថ និងផលិតផលសុខាភិបាលដែលផុតកំណត់ប្រើប្រាស់ ឬខូចគុណភាព និងត្រូវទុកដាក់នៅកន្លែងមានសុវត្ថិភាព ។
- ពិនិត្យមើលរកសត្វកកេរ សត្វល្អិត ឬ ដំបូលលេចឬជ្រាប

ការងារប្រចាំខែ

- ធ្វើបច្ចុប្បន្នភាពសលាកបត្រឃ្លាំង
- ធ្វើសារពើភ័ណ្ឌដោយដៃ ឬរាប់តាមវដ្ត (cycle count) និងធ្វើបច្ចុប្បន្នភាពកំណត់ត្រាស្តុក
- ធានាឲ្យមានចរន្តអគ្គីសនីជាប្រចាំ ដើម្បីរក្សានីរន្តភាពការងារ ដូចជាពិនិត្យមើលប្រេង និង បន្ថែមប្រេងក្នុងករណីចាំបាច់
- ត្រួតពិនិត្យមើលរចនាសម្ព័ន្ធអគារឃ្លាំងដើម្បីរកមើលការបែកបាក់ រួមមាន ជញ្ជាំង ដំបូល បង្អួច និងទ្វារ។

ការងារប្រចាំត្រីមាស

- ធ្វើសារពើភ័ណ្ឌដោយដៃ ឬរាប់តាមវដ្ត (cycle count) និងធ្វើបច្ចុប្បន្នភាពកំណត់ត្រាស្តុក
- ប្រើនីតិវិធីនានាដែលមានដើម្បីដកយកឱសថ និងផលិតផលសុខាភិបាលដែលផុតកំណត់ប្រើប្រាស់ ឬបែកបាក់ ឬខូចគុណភាពចេញពីលើធ្នើរ
- ត្រួតពិនិត្យបំពង់ពន្លត់អគ្គីភ័យដើម្បីធានាថានៅតែអាចប្រើប្រាស់បាន ។

ការងារដែលត្រូវធ្វើដើម្បីស្នើសុំជាថ្មី ឬបញ្ជាទិញនិងធ្វើរបាយការណ៍ប្រចាំខែ ឬត្រីមាស :

- វាយតម្លៃស្ថានភាពស្តុក
- បំពេញ និងបញ្ជូនរបាយការណ៍ស្នើសុំ កំណត់បញ្ហា និងទំហំបញ្ហា
- ទទួលឱសថ និងផលិតផលសុខាភិបាល
- រៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលដោយប្រើប្រាស់នីតិវិធីត្រឹមត្រូវ តាមគោលការណ៍ ជិតផុតកាលកំណត់ប្រើបញ្ចេញមុន "FEFO" ឬ ចូលមុនបញ្ចេញប្រើមុន "FIFO" (ចូរមើលនៅផ្នែកទទួល និងផ្នែករៀបចំ)
- បំពេញរបាយការណ៍ស្នើសុំ និងរៀបចំទុកដាក់ឯកសារ

ការងារប្រចាំឆមាស

- ហ្វឹកហាត់ពីរបៀបពន្លត់អគ្គីភ័យ និងពិនិត្យឡើងវិញលើនីតិវិធីពន្លត់អគ្គីភ័យ
- ត្រួតពិនិត្យមើលដើមឈើនៅក្បែរឃ្លាំង និងកាត់តម្រឹមមែកឈើ
- មានកម្មវិធីកំចាត់សត្វល្អិត សត្វកកេរ

ការងារប្រចាំឆ្នាំ

- ត្រួតពិនិត្យប្រព័ន្ធពន្លត់អគ្គីភ័យ ថែរក្សាបំពង់ពន្លត់អគ្គីភ័យ និងឧបករណ៍ពិនិត្យមើលផ្សេង
- ធ្វើបញ្ជីសារពើភ័ណ្ឌឲ្យពេញលេញ និងធ្វើបច្ចុប្បន្នភាពកំណត់ត្រាស្តុក
- វាយតម្លៃឡើងវិញទៅលើកម្រិតស្តុក និងកែតម្រូវ បើសិនចាំបាច់ ។

*រក្សាឃ្លាំងឲ្យបានស្អាតនិងមានរបៀបរៀបរយ*

*ធ្វើឲ្យមានការងាយស្រួលក្នុងការគ្រប់គ្រងឱសថ បរិក្ខារពេទ្យ*

*និងផលិតសុខាភិបាល*

## ១. ការទទួល និងការរៀបចំឱសថ និងផលិតផលសុខាភិបាល

### ១.១. ការទទួលឱសថនិងផលិតផលសុខាភិបាល

តើអ្នកទទួលឱសថ និងផលិតផលសុខាភិបាលនៅពេលណា ?

- ធានាថាមានកន្លែងគ្រប់គ្រាន់
- រៀបចំនិងសម្អាតកន្លែងទទួល និងកន្លែងរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល

- ត្រួតពិនិត្យឱសថ និងផលិតផលសុខាភិបាលណា ដែលបែកបាក់ឬផុតកំណត់ប្រើប្រាស់ ឬខូចគុណភាព
- រៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលតាមទីកន្លែងសមស្រប ។

| **ប្រសិនបើ** | **ការងារដែលត្រូវធ្វើ** |
|---|---|
| ឱសថ និងផលិតផលសុខាភិបាលដែលបែកបាក់ ឬផុតកំណត់ប្រើ ឬខូចគុណភាព | ១. រៀបចំទុកដាក់ដោយឡែកពីឱសថ និងផលិតផលសុខាភិបាលដែលនៅប្រើបាន<br>២. ពេលរកឃើញមានឱសថ និងផលិតផលសុខាភិបាលដែលបែកបាក់ ឬផុតកំណត់ប្រើ ឬខូចគុណភាព អំឡុងពេលដឹកជញ្ជូន ត្រូវកត់ត្រាបញ្ហានេះទៅក្នុងកំណត់ត្រាដឹកជញ្ជូន<br>៣. ពេលរកឃើញមានឱសថ និងផលិតផលសុខាភិបាលដែលបែកបាក់ ឬផុតកំណត់ប្រើ ឬខូចគុណភាព ក្រោយពេលដឹកជញ្ជូន គឺត្រូវអនុវត្តតាមគោលការណ៍នៃការរៀបចំទុកដាក់ដោយឡែក<br>៤. បំពេញកំណត់ហេតុស្តីពីឱសថ និងផលិតផលសុខាភិបាលខូចគុណភាព រួចផ្ញើមកការិយាល័យឱសថសារវន្ត នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យនិងគ្រឿងសំអាង (ឧបសម្ព័ន្ធទី 3) សម្រាប់សេវាសាធារណៈ |
| ឱសថ និងផលិតផលសុខាភិបាល ដែលគ្មានការបែកបាក់ឬផុតកំណត់ប្រើ ឬខូចគុណភាព | ១. រាប់ចំនួនឯកតានៃឱសថ និងផលិតផលសុខាភិបាលនិមួយៗ ដែលបានទទួល និងផ្ទៀងផ្ទាត់ជាមួយវិក្កយបត្រ រួចធ្វើកំណត់ហេតុបញ្ចូលឃ្លាំង<br>២. កត់ត្រាក្នុងសលាកបត្រឃ្លាំង និងសលាកបត្រឃ្លាំងព្យួរឲ្យបានត្រឹមត្រូវ<br>៣. ធានាឲ្យមានថ្ងៃខែឆ្នាំផុតកំណត់ប្រើ នៅលើកញ្ចប់ឬប្រអប់ឲ្យបានច្បាស់ ចំពោះឱសថ<br>៤. រៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល តាមគោលការណ៍ ជិតផុតកំណត់ប្រើបញ្ចេញមុន " FEFO " និងចូលមុនបញ្ចេញប្រើមុន "FIFO"(ចូរមើលផ្នែកបង្ហិលស្តុក) |

*ចូរពិនិត្យកាលបរិច្ឆេទផុតកំណត់ប្រើ គុណភាពឱសថនិង*

*ផលិតផលសុខាភិបាល មុនពេលរក្សាទុកក្នុងឃ្លាំង !*

### ១.២. ការរៀបចំឱសថ និងផលិតផលសុខាភិបាល

**ការរៀបចំឃ្លាំង និងធ្នើរ ៖**

បើសិនប្រើទម្រ (Pallet) ត្រូវគរកេសឬឡាំងពីលើទម្រ

- ទម្រត្រូវមានកំពស់ ១០ ស.ម ពីកម្រាលឥដ្ឋ
- ទម្រត្រូវមានគម្លាត ៣០ ស.ម ពីជញ្ជាំង និងពីគំនរដំទៃទៀត
- កម្ពស់គំនររបស់ឱសថ និងផលិតផលសុខាភិបាលមិនឲ្យលើសពី ២,៥០ ម

**ការរៀបចំទុកដាក់៖**

- អនុវត្តតាមការណែនាំរបស់អ្នកផលិត ឬអ្នកដឹកជញ្ជូននៅពេលដាក់ឱសថ និងផលិតផលសុខាភិបាលលើគ្នា និងរៀបចំទុកដាក់តាមលក្ខខណ្ឌតម្រូវដែលមានសរសេរលើប្រអប់ ឬកេស
- ដាក់ឱសថ និងផលិតផលសុខាភិបាលរាវលើធ្នើរដែលទាបជាងគេ ឬគរនៅខាងក្រោម
- រៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលណាដែលតម្រូវឲ្យដាក់កន្លែងត្រជាក់តាមលក្ខខណ្ឌតម្រូវ
- រៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលណាដែលត្រូវការមានសុវត្ថិភាព និងតម្លៃខ្ពស់នៅកន្លែងដែលមានសុវត្ថិភាពគ្រប់គ្រាន់
- រៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលដែលបែកបាក់ ផុតកំណត់ប្រើ ឬខូចគុណភាពឲ្យដាច់ដោយឡែកពីឱសថ និងផលិតផលសុខាភិបាលដែលនៅប្រើបាន ដោយមិនពន្យារពេល និងកំទេចចោលដោយប្រើនីតិវិធីដែលមានស្រាប់
- រៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលតាមគោលការណ៍ ជិតផុតកំណត់ប្រើមុនបញ្ចេញមុន " FEFO " សម្រាប់ការគ្រប់គ្រងស្តុក និងចូលមុនចេញប្រើមុន " FIFO "
- រៀបចំកេស ឬឡាំងជាជួរៗដោយឲ្យឃើញស្លាកសញ្ញាថ្ងៃខែឆ្នាំផុតកំណត់ប្រើ ថ្ងៃខែឆ្នាំផលិត បើសិនមិនឃើញ ច្បាស់ត្រូវសរសេរដោយដៃ។

### ១.៣. ការបង្វិលស្តុកឱសថ និងផលិតផលសុខាភិបាល

នៅពេលបញ្ចេញឱសថ និងផលិតផលសុខាភិបាល ចាំបាច់ត្រូវអនុវត្តតាមគោលការណ៍ ជិតផុតកំណត់ប្រើមុនបញ្ចេញមុន " FEFO " និងចូលមុនចេញប្រើមុន " FIFO " ។

ការអនុវត្តគោលការណ៍ ជិតផុតកំណត់ប្រើមុនបញ្ចេញមុន " FEFO " កាត់បន្ថយឱសថ និងផលិតផលសុខាភិបាលដែលផុតកំណត់ប្រើ ។

- ត្រូវបញ្ចេញឱសថ និងផលិតផលសុខាភិបាលដែលជិតផុតកំណត់ប្រើមុន ដោយធានាថាឱសថ និងផលិតផលសុខាភិបាលទាំងនោះ មិនមានថ្ងៃខែផុតកំណត់ប្រើកៀកពេក
- ដើម្បីសម្រួលដល់ការអនុវត្តគោលការណ៍ ជិតផុតកំណត់ប្រើមុនបញ្ចេញមុន " FEFO " គឺត្រូវដាក់ឱសថ និងផលិតផលសុខាភិបាលដែលជិតផុតកំណត់ប្រើនៅពីមុខគេ និងរៀបតាមលំដាប់លំដោយនៃថ្ងៃខែផុតកំណត់ប្រើ
- សរសេរថ្ងៃខែឆ្នាំផុតកំណត់ប្រើលើសលាកបត្រឃ្លាំង ដូច្នេះឱសថ និងផលិតផលសុខាភិបាលដែលត្រូវបានបញ្ជូនចេញយ៉ាងតិចមានអាយុកល្ប៦ខែ។ ចូរចងចាំថា ការទទួលឱសថ និងផលិតផលសុខាភិបាល មិនចាំបាច់គិតតាមលំដាប់នៃថ្ងៃខែឆ្នាំផុតកំណត់ប្រើឡើយ។ ឱសថ និងផលិតផលសុខាភិបាលដែលទើបទទួល អាចមានថ្ងៃខែឆ្នាំផុតកំណត់ប្រើខ្លីជាងឱសថ និងផលិតផលសុខាភិបាលដែលបានទទួលពីមុន។ ដូច្នេះជាការចាំបាច់ត្រូវពិនិត្យមើលថ្ងៃខែឆ្នាំ

ផុតកំណត់ប្រើ ដើម្បីធានាកុំឲ្យមានឱសថ និងផលិតផលសុខាភិបាលផុតកំណត់ប្រើអំឡុងពេលស្តុក។

### ១.៤. ការរៀបចំឱសថ និងផលិតផលសុខាភិបាល

ឃ្លាំងស្តុកឱសថ និងផលិតផលសុខាភិបាលត្រូវមានប្រព័ន្ធការងារមួយ សម្រាប់ធ្វើចំណាត់ថ្នាក់ឬរៀបចំឱសថ និងត្រូវធានាឲ្យបុគ្គលិកដែលពាក់ព័ន្ធទាំងអស់ យល់ដឹងអំពីប្រព័ន្ធការងារដែលកំពុងអនុវត្តនោះ ។

ប្រព័ន្ធរៀបចំឱសថ និងផលិតផលសុខាភិបាលដែលនិយមប្រើមាន ៖

*ការរៀបចំតាមលំដាប់តួអក្សរឈ្មោះហ្សេនេរិក (Generic) ៖* ប្រព័ន្ធនេះតែងឃើញមាននៅទាំងឃ្លាំងធំ និងឃ្លាំងតូច ។ ពេលប្រើប្រព័ន្ធនេះ ស្លាកសញ្ញាត្រូវបានផ្លាស់ប្តូរ ពេលបញ្ជីឱសថសារវន្តបានធ្វើបច្ចុប្បន្នភាពរួច ។

*ការរៀបចំតាមប្រភេទឱសថវិទ្យា ឬតាមប្រភេទព្យាបាល ៖* ការរៀបចំនេះមានប្រយោជន៍បំផុតចំពោះឃ្លាំងតូច ឬឱសថស្ថានរាយដែលបុគ្គលិកឃ្លាំងមានការយល់ដឹងយ៉ាងច្បាស់អំពីឱសថវិទ្យា (Pharmacology) ។

*ការរៀបចំតាមទម្រង់ឱសថ ៖* ឱសថមានទម្រង់ខុសៗគ្នា ដូចជាគ្រាប់ ស៊ីរ៉ូ ឱសថចាក់ ឱសថលាបលើស្បែកដែលមានសណ្ឋានជាប៉ូម៉ាត (Ointments) និងក្រែម (Cream) ។ នៅក្នុងប្រព័ន្ធការងារនេះ ឱសថត្រូវបានរៀបចំទុកដាក់តាមទម្រង់របស់វា។ វិធីស្តុកតាមបែបដទៃទៀតក៏អាចយកមកប្រើក្នុងការរៀបចំទុកដាក់ឱសថបានដែរ ។

*ការរៀបចំតាមរបៀបប្រើប្រាស់ញឹកញាប់ ៖* ឱសថដែលប្រើញឹកញាប់ ត្រូវដាក់នៅពីមុខឱសថដទៃទៀតក្នុងឃ្លាំង ឬជិតច្រកចេញ ។ ប្រព័ន្ធការងារនេះ ត្រូវអនុវត្តជាមួយប្រព័ន្ធដទៃទៀត។

*ការរៀបចំតាមលេខកូដទីតាំង ៖* ឱសថនីមួយៗមានសរសេរអក្សរ និងលេខកូដទីតាំង។ ប្រព័ន្ធការងារនេះមានភាពបត់បែន ប៉ុន្តែពិបាកយល់ផងដែរ ។ មន្ត្រីឃ្លាំងមិនចាំបាច់មានចំណេះដឹងបច្ចេកទេសផ្នែកឱសថទេ ក្នុងការគ្រប់គ្រងប្រព័ន្ធការងារនេះ ពីព្រោះលេខកូដមានព័ត៌មានសម្រាប់ការទុកដាក់ឱសថឲ្យបានត្រឹមត្រូវ ដូចជាសីតុណ្ហភាព កម្រិតសុវត្ថិភាព និងភាពដែលអាចឆេះ ។ ប្រព័ន្ធការងារនេះអនុវត្តបានល្អនៅក្នុងប្រព័ន្ធត្រួតពិនិត្យសារពើភ័ណ្ឌដោយកុំព្យូទ័រ ។

| |
|---|
| *រៀបចំឱសថ និងផលិតផលសុខាភិបាលឲ្យមានរបៀប ធ្វើឲ្យងាយស្រួលក្នុងការគ្រប់គ្រង* |

## ២. ការរក្សាឯកសារគ្រប់គ្រងឱសថ និងផលិតផលសុខាភិបាលនៅក្នុងឃ្លាំង

### ២.១. បញ្ជីរាយមុខឱសថ និងផលិតផលសុខាភិបាល

- ឃ្លាំងនីមួយៗត្រូវរក្សាបញ្ជីរាយមុខឱសថ និងផលិតផលសុខាភិបាលទាំងអស់ដែលត្រូវប្រើ ដែលមានបញ្ជាក់ លក្ខណៈបច្ចេកទេសរបស់វារួមមាន ទម្រង់ កម្រិតសារធាតុសកម្ម និងបរិមាណក្នុងប្រអប់នីមួយៗ។
- ត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីនេះឲ្យបានទៀងទាត់ រួចចែកឲ្យឱសថស្ថានរាយ និងអង្គភាពពាក់ព័ន្ធ។
- ហាមស្នើសុំឱសថ និងផលិតផលសុខាភិបាលដែលមិនមានក្នុងបញ្ជីរាយមុខឱសថ បើមិនមានការអនុញ្ញាត ពិសេសចំពោះសេវាសាធារណៈ។ មិនត្រូវចែកចាយឱសថ និងផលិតផលសុខា

ភិបាលដែលមិនមានក្នុងបញ្ជីរាយមុខឱសថ និងផលិតផលសុខាភិបាល បើមិនមានបញ្ជាក់ករណីពិសេសណាមួយនោះទេ។

- កំណត់ត្រាសារពើភ័ណ្ឌត្រូវធ្វើលើគ្រប់ឱសថ និងផលិតផលសុខាភិបាលទាំងអស់ដែលមានក្នុងបញ្ជី។

## ២.២ សលាកបត្រឃ្លាំង

- ព័ត៌មានមួយចំនួនអំពីឱសថ និងផលិតផលសុខាភិបាល ត្រូវមាននៅក្នុងសលាកបត្រឃ្លាំង ៖

❖ ឈ្មោះ/ការបរិយាយ (រួមទាំង ទម្រង់ កាប់ស៊ុល គ្រាប់ អង្គធាតុរាវ ។ល។) និងកម្រិតសារធាតុសកម្ម

❖ ស្តុកបច្ចុប្បន្ន

❖ ចំនួនទទួល

❖ ចំនួនបញ្ចេញ

❖ ចំនួនបាត់បង់/កែតម្រូវ

❖ តុល្យការ (ចុងបញ្ចប់)

❖ ឯកសារយោង (ឧ. លេខវិក្កយបត្រ ឬឈ្មោះអ្នកផ្គត់ផ្គង់ឬអ្នកទទួល)។

- អាស្រ័យលើប្រព័ន្ធ សលាកបត្រឃ្លាំងក៏អាចបញ្ចូលផងដែរនូវព័ត៌មានបន្ថែមរបស់ឱសថ និងផលិតផល សុខាភិបាលដូចជា៖

❖ លក្ខខណ្ឌទុកដាក់ពិសេស (ឧ. 2°C ទៅដល់ 8°C)

❖ តម្លៃឯកតា

❖ លេខឡូត៍ ឬលេខកូដទីតាំងស្តុក

❖ លេខកូដឱសថ និងផលិតផលសុខាភិបាល

❖ ថ្ងៃខែឆ្នាំផុតកំណត់ប្រើ ។

- សលាកបត្រឃ្លាំងមានទិន្នន័យឱសថ និងផលិតផលសុខាភិបាល មួយចំនួនសម្រាប់គណនាបរិមាណ ដូចតទៅ៖

❖ទិន្នន័យប្រើប្រាស់ឬបញ្ចេញ ដូចជាចំនួនប្រើប្រាស់ឬបញ្ចេញជាមធ្យមប្រចាំខែ(AMC) ឬចំនួនប្រើប្រាស់ឬបញ្ចេញលក់ប្រចាំថ្ងៃ ចំពោះសេវាឯកជន

❖ រយៈពេលស្នើសុំ ឬបញ្ជាទិញរហូតដល់ពេលបានទទួលឱសថ និងផលិតផលសុខាភិបាល (Lead times)

❖ ចំនួនអតិបរមា និងអប្បបរមានៃការស្តុក

❖ ចំនួនស្នើសុំ ឬបញ្ជាទិញបន្ទាន់។

- ប្រព័ន្ធរៀបចំទុកដាក់និងប្រព័ន្ធចែកចាយ មិនចាំបាច់ប្រើគ្រប់ទម្រង់ទាំងអស់នេះទេ ប៉ុន្តែអាចត្រូវការទម្រង់ដែលកត់ត្រាទិន្នន័យរក្សាស្តុក និងទិន្នន័យបញ្ចេញ-បញ្ចូល។ ទម្រង់ស្តង់ដារ (ឯកសារគំរូ) ដែលប្រើសម្រាប់ត្រួតពិនិត្យសារពើភ័ណ្ឌ រួមមាន៖

❖ សលាកបត្រឃ្លាំង និង/ឬ ប្រើក្នុងកុំព្យូទ័រ

❖ សលាកបត្រឃ្លាំងព្យួរ

❖ វិក្កយបត្របញ្ចូល

❖ ឯកសារទទួល (ឯកសារដឹកជញ្ជូន) (packing slip/freight bill)

❖ ប័ណ្ណប្រគល់

❖ កំណត់ហេតុឱសថហួសកាលកំណត់ប្រើ ឬខូចគុណភាព

❖ បញ្ជីឱសថ និងផលិតផលសុខាភិបាល និងតម្លៃ

❖ ទម្រង់សារពើភ័ណ្ឌ (Physical inventory forms) ។

| |
|---|
| *រក្សាកំណត់ត្រាដែលត្រឹមត្រូវ ធ្វើឲ្យងាយស្រួលក្នុងការអនុវត្តការងារ* |

## ២.៣. ការធ្វើសារពើភ័ណ្ឌដោយដៃ (Physical inventory)

ការធ្វើសារពើភ័ណ្ឌជាដំណើរការរាប់ដោយដៃនូវចំនួនឱសថ និងផលិតផលសុខាភិបាលមួយមុខៗដែលមានក្នុងស្តុក តាមពេលវេលាណាមួយដែលបានកំណត់។ការធ្វើសារពើភ័ណ្ឌធានាឲ្យបរិមាណដែលកំពុងមានក្នុងឃ្លាំង ត្រូវបានកត់ត្រាត្រឹមត្រូវដូចនៅក្នុងសលាកបត្រឃ្លាំង។ ពេលធ្វើសារពើភ័ណ្ឌត្រូវរាប់ឱសថ និងផលិតផលសុខាភិបាលនិមួយៗដោយផ្អែកលើឈ្មោះហ្សេនេរិក ឬពាណិជ្ជនាម ទម្រង់ និងកម្រិតសាធាតុសកម្មឱសថ និងផលិតផលសុខាភិបាល។

**ការធ្វើសារពើភ័ណ្ឌមានពីរប្រភេទ៖**

❖ ***ការធ្វើសារពើភ័ណ្ឌ**គ្រប់មុខ៖* ឱសថ និងផលិតផលសុខាភិបាលទាំងអស់ ត្រូវរាប់តាមពេលវេលា ដែលបាន កំណត់។ ការធ្វើសារពើភ័ណ្ឌគ្រប់មុខគឺត្រូវរាប់យ៉ាងតិចណាស់មួយឆ្នាំម្តង អាចរាប់ ញឹកញាប់ជាងនេះគឺ មួយត្រីមាស ឬមួយខែម្តង ។ ចំពោះឃ្លាំងធំអាចតម្រូវឲ្យបិទឃ្លាំងរយៈពេលមួយថ្ងៃយ៉ាងតិច។

❖ ***ការធ្វើសារពើភ័ណ្ឌ ឬដោយកំណត់ចំនួន ឬចៃដន្យ៖*** ឱសថ និងផលិតផលសុខាភិបាល ដែលបាន ជ្រើសរើសរួចហើយ ត្រូវរាប់ និងពិនិត្យដោយផ្ទៀងផ្ទាត់ជាមួយសលាកបត្រឃ្លាំងរយៈពេលមួយឆ្នាំ ។

ការធ្វើសារពើភ័ណ្ឌគ្រប់មុខ ជាការរាប់ដែលងាយ និងទៀងទាត់នៅក្នុងឃ្លាំងទាំងឡាយណាដែលមាន បរិមាណ ឱសថ និងផលិតផលសុខាភិបាលតិច។ ការធ្វើសារពើភ័ណ្ឌតាមវដ្ត ***ឬដោយកំណត់ចំនួន*** ឬ***ចៃដន្យ*** គឺតែងតែធ្វើលើឃ្លាំងទាំងឡាយណា ដែលមានបរិមាណឱសថ និងផលិតផលសុខាភិបាលច្រើន។

**ការធ្វើសារពើភ័ណ្ឌតាមវដ្ត អាចរាប់តាមវិធីជាច្រើនដូចតទៅ៖**

❖ ***តាមទម្រង់ឱសថ៖*** រាប់ឱសថគ្រាប់នៅក្នុងខែមករា រាប់ឱសថកាប់ស៊ុលនៅខែកុម្ភៈ រាប់ឱសថរាវ នៅខែមិនា ។ល។

❖ ***តាមកន្លែងក្នុងឃ្លាំង៖*** រាប់នៅលើធ្នើរលេខ១ដល់៤នៅខែមករា លេខ៥ដល់៨ នៅខែកុម្ភៈ ។ល។

❖ ***រាប់តាមពេលវេលា៖*** រាប់ពីរទៅបីមុខក្នុងមួយថ្ងៃនៅពេលដែលអ្នកមានពេល ។

❖ ***ស្តុកបច្ចុប្បន្ន៖*** ក្នុងរយៈពេលណាមួយ រាប់ឱសថ និងផលិតផលសុខាភិបាលមួយមុខៗដែលមានក្នុងឃ្លាំង នៅកម្រិត ឬក្រោមកម្រិតអប្បបរិមានៃសារពើភ័ណ្ឌ។

ប្រសិនបើធ្វើសារពើភ័ណ្ឌតាមវដ្ត ចូររាប់ឱសថ និងផលិតផលសុខាភិបាលមួយមុខៗយ៉ាងតិចម្តងក្នុងមួយឆ្នាំ។ រាប់ឱសថ និងផលិតផលសុខាភិបាលណាដែលមានចលនាចេញចូល និងផ្គត់ផ្គង់ឬចែកចាយញឹកញាប់ ឲ្យបានត្រឹមត្រូវ។

**ដំណាក់កាលធ្វើសារពើភ័ណ្ឌ ៖**

(១) **ផែនការ**

- ចំពោះការធ្វើសារពើភ័ណ្ឌគ្រប់មុខ ត្រូវធ្វើតារាងពេលវេលានិងថ្ងៃខែឆ្នាំ

- ចំពោះការធ្វើសារពើភ័ណ្ឌតាមវដ្ត ឬដោយកំណត់ចំនួន ឬចៃដន្យ ត្រូវកំណត់ឱសថ និងផលិតផលសុខាភិបាលណាខ្លះ ដែលត្រូវរាប់ និងកំណត់ពេលវេលាសម្រាប់ប្រតិបត្តិការ។

(២) **កំណត់យកបុគ្គលិក**

(៣) **រៀបចំឃ្លាំង**

- រៀបឱសថ និងផលិតផលសុខាភិបាល តាមគោលការណ៍ផុតកំណត់ប្រើមុនបញ្ចេញមុន (FEFO)
- ធានាថាកេស និងប្រអប់ឱសថ និងផលិតផលសុខាភិបាលត្រូវបានបើក
- ដាក់ដោយឡែកចំពោះឱសថ និងផលិតផលសុខាភិបាលខូចឬហួសកាលកំណត់ប្រើ ។

(៤) **រាប់ឱសថ និងផលិតផលសុខាភិបាលដែលនៅមានសុពលភាពប្រើ**

- រាប់ឱសថ និងផលិតផលសុខាភិបាល តាមចំនួនឯកតាដែលត្រូវបញ្ចេញ (ឧ. គ្រាប់ ឬ បន្ទះ ។ល។) ដោយមិនរាប់តាមចំនួនកេស ឬចំនួនប្រអប់ឡើយ ចំពោះសេវារដ្ឋ ។ អាចរាប់ចំនួនប្រអប់ ឬចំនួនកេស ចំពោះសេវាឯកជន ។
- ប៉ាន់ប្រមាណបរិមាណនៅក្នុងឧបករណ៍វេចខ្ចប់ ដែលបានបើកចំពោះឱសថ និងផលិតផលសុខាភិបាលណា ដែលដាក់ក្នុងឧបករណ៍វេចខ្ចប់ធំៗ ។ បើសិនក្នុងដបមានចំនួន១០០០ កាប់ស៊ុល ហើយនៅមានកាប់ស៊ុលប្រហែល ២ភាគ៣ គឺត្រូវប៉ាន់ប្រមាណថាប្រហែល មាន ៦៥០ កាប់ស៊ុល ឬ៧០០កាប់ស៊ុល។ បើសិនស៊ីរ៉ូដាក់ក្នុងដបចំណុះ១លីត្រហើយឃើញមាននៅពាក់កណ្តាល ត្រូវប៉ាន់ប្រមាណថាមានកន្លះលីត្រ។

(៥) **ធ្វើបច្ចុប្បន្នភាពសលាកបត្រឃ្លាំង**

- កត់ត្រាកាលបរិច្ឆេទនៃការធ្វើសារពើភ័ណ្ឌនិងកត់ត្រាលទ្ធផលពី «ការធ្វើសារពើភ័ណ្ឌ»
- ប្រើ ***ទឹកប៊ិចពណ៌ក្រហម*** កត់ត្រាបរិមាណឱសថ និងផលិតផលសុខាភិបាលដែលបានរាប់នៅក្នុងឃ្លាំង។

(៦) **អនុវត្តសកម្មភាពដោយផ្អែកលើលទ្ធផលនៃការធ្វើសារពើភ័ណ្ឌ**

- ប្រសិនបើ លទ្ធផលនៃការធ្វើសារពើភ័ណ្ឌ ខុសពីតុល្យការនៅក្នុងសលាកបត្រឃ្លាំង ឬ សលាកបត្រឃ្លាំងព្យួរ ត្រូវធ្វើបច្ចុប្បន្នភាពតុល្យការដោយបន្ថែមឬបន្ថយបរិមាណដែលខុស (លើសឬខ្វះ)
- ដកចេញឱសថ និងផលិតផលសុខាភិបាលបែកបាក់ ឬហួសកាលកំណត់ប្រើដែលបានរកឃើញ អំឡុងពេលធ្វើសារពើភ័ណ្ឌ រួចធ្វើកំណត់ហេតុស្នើសុំកំទេច
- ចំពោះបញ្ហានិមួយៗដែលបានរកឃើញដូចខាងលើ ត្រូវកំណត់អត្តសញ្ញាណ ធ្វើកំណត់ហេតុ និង កែតម្រូវមូលហេតុនៃបញ្ហា ។

(៧) **ពិភាក្សាជាមួយ**មន្ត្រីឬបុគ្គលិក**អំពីលទ្ធផលនៃការធ្វើសារពើភ័ណ្ឌ**

- ទទួលយកយោបល់របស់មន្ត្រីឬបុគ្គលិក បើយោបល់នោះសមស្រប
- កែតម្រូវសកម្មភាព បើសិនជាមានតម្រូវការចាំបាច់។

*ការធ្វើសារពើភ័ណ្ឌ ជួយយើងឲ្យដឹងពីចំនួនដែលមានក្នុងស្តុក និងពេលវេលាស្នើសុំជាថ្មី ឬបញ្ជាទិញថ្មី*

## ៣.លក្ខខណ្ឌពិសេសនៃការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល

ឱសថមួយចំនួន ត្រូវរៀបចំទុកដាក់ក្នុងស្ថានភាពមួយដែលអាចត្រួតពិនិត្យបានយ៉ាងងាយ ។

ជាការសំខាន់ចំពោះការកំណត់អត្តសញ្ញាណឱសថ ដែលមានហានិភ័យនៃចោរកម្ម ឬការប្រើប្រាស់ ដោយរំលោភ ឬអាចឲ្យញៀនរួមទាំង ឱសថដែលមានតម្រូវការខ្ពស់ (ទីផ្សារងងឹត) ត្រូវបង្កើនសុវត្ថិភាពខ្ពស់ចំពោះឱសថទាំងនេះ ។

### ៣.១ ឧទាហរណ៍នៃការរៀបចំទុកដាក់ឱសថនិងផលិតផលសុខាភិបាលដែលអាចឲ្យត្រួតពិនិត្យបាន

ជាទូទៅក្នុងបញ្ជីឱសថសារវន្ត មានឱសថញៀន និងឱសថប៉ះពាល់ផ្លូវចិត្ត ដូច្នេះអាចមានឱសថប្រភេទនេះ មួយឬពីរមុខ នៅក្នុងបញ្ជី ។

***ឱសថញៀន*** ដូចជា Morphine, Oxycodone , Tramadol , Codeine , Opium preparations ។ល។

***ឱសថប៉ះពាល់ផ្លូវចិត្ត*** ដូចជា ឱសថដែលគេស្គាល់ច្រើនជាងគេមានជាអាទិ៍ Diazepam និងឱសថដែលមានក្នុងបញ្ជីឱសថសារវន្ត ដែលក្នុងនោះមានដូចជា Carbamazepine ដែលប្រើសម្រាប់ព្យាបាលជំងឺឆ្កួតជ្រូក និងឱសថធ្វើឲ្យស្ងប់អារម្មណ៍ដូចជា chlorpromazine ។

ឱសថមួយចំនួនដែលបានរៀបរាប់ខាងលើ គឺឱសថដែលត្រូវត្រួតពិនិត្យតាមលក្ខខណ្ឌអន្តរជាតិ។ ឱសថទាំងនេះ ត្រូវយកចិត្តទុកដាក់ជាងឱសថធម្មតា។ មាននីតិវិធីពិសេសកំពុងដាក់ឲ្យអនុវត្ត សម្រាប់ធ្វើលទ្ធកម្ម ឬអាហារ័ណ នីហារ័ណ ទទួលទុកដាក់ ចែកចាយ និងប្រើប្រាស់។ (ទម្រង់ ស្នើសុំពិសេសត្រូវដាក់ឲ្យប្រើចំពោះ ឱសថ ប្រភេទនេះ )។

- ឱសថញៀន និងឱសថប៉ះពាល់ផ្លូវចិត្ត ត្រូវរក្សាទុកដោយអនុលោមតាមអនុសញ្ញាអន្តរជាតិ ច្បាប់ និងបទដ្ឋានជាតិ និងបង្កើតច្រកសម្រាប់ងាយត្រួតពិនិត្យអំពីការរក្សាទុក ។ ឱសថទាំងនេះ ត្រូវរក្សាទុកដូចខាងក្រោម ៖
  - ❖មានបន្ទប់ដាច់ដោយឡែក ទូចាក់សោរ ឬកន្លែងសុវត្ថិភាព
  - ❖ មានទូធ្វើអំពីដែកនៅក្នុងឃ្លាំង ។
- ដាក់ភ្លើងឲ្យបញ្ចេញសញ្ញានិងសំឡេង នៅពេលមានអ្នកចេញចូលដោយគ្មានការអនុញ្ញាត។
- ការចូលក្នុងឃ្លាំងឱសថដែលតម្រូវឲ្យត្រួតពិនិត្យ អាចអនុញ្ញាតបានតែនាយឃ្លាំង ឬឱសថការីជាមួយបុគ្គលិកឃ្លាំងមួយរូបទៀត ។
- កំណត់ចំនួនបុគ្គលិកដែលកាន់សោរឃ្លាំង និងធ្វើបញ្ជីឈ្មោះបុគ្គលិកទាំងនោះ ។

***ចំណាំ៖*** *ឱសថដទៃទៀតរួមទាំងឱសថប្រឆាំងវីរុស ដែលប្រើសម្រាប់ព្យាបាលជំងឺអេដស៍ អាចតម្រូវឲ្យរៀបចំទុកដាក់នៅក្នុងឃ្លាំងដែលត្រួតពិនិត្យតឹងរឹង ពីព្រោះឱសថទាំងនោះពុំសូវមាន ហើយមានតម្លៃថ្លៃ និងតម្រូវការខ្ពស់។ អង្គការដែលផ្តល់ឱសថ តម្រូវឲ្យទុកដាក់ក្នុងស្ថានភាពងាយត្រួតពិនិត្យ។ ឱសថប្រភេទនេះអាចធ្វើអំណោយក្នុងលក្ខខណ្ឌណាមួយច្បាស់ លាស់ និងដែលអាចប្រើក្នុងលក្ខខណ្ឌដទៃទៀតបាន។ ឧទាហរណ៍៖ ឱសថសម្រាប់ព្យាបាលជំងឺកាមរោគដែលមានក្នុងបញ្ជីឱសថសារវន្ត ហើយឱសថទាំងនេះក៏អាចប្រើសម្រាប់ព្យបាលជំងឺដទៃទៀតបានដែរ ។ ឧបករណ៍តេស្តមេរោគហ៊ីវ (HIV) ដែលបានធ្វើអំណោយ សម្រាប់កម្មវិធីនានា ដូចជាកម្មវិធីបង្ការការចម្លងមេរោគហ៊ីវ (HIV) ពីម្តាយទៅកូន ក៏អាចប្រើសម្រាប់គោលដៅដទៃទៀតដែរ ដូចជាប្រើសម្រាប់ធានាសុវត្ថិភាពឈាម ។*

### ៣.២ ឧបករណ៍និងសម្ភារៈសម្រាប់រៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល

**ធ្នើរ និងទូ៖** ប្រើធ្នើរ និងទូ ដើម្បីទុកដាក់ឱសថ និងផលិតផលសុខាភិបាលណាដែលតូចៗ។ កែធ្នើរតាមទំហំកេសខុសៗគ្នា។

**តុនៅកន្លែងវេចខ្ចប់៖** ត្រូវមានតុធំនៅកន្លែងវេចខ្ចប់សម្រាប់បុគ្គលិកប្រើពេលវេចខ្ចប់ និងបញ្ជូនឥវ៉ាន់ ហើយតុនោះត្រូវមានភាពរលីងស្អាត។

**កំណាល់៖** កំណាល់ត្រូវប្រើសម្រាប់ទុកដាក់ឱសថ និងផលិតផលសុខាភិបាលនិងកេសធំៗ។ កំណាល់ត្រូវកល់ផលិតផលឲ្យផុតពីឥដ្ឋ និងអាចប្រើជាមួយរថយន្តសម្រាប់លើកដាក់ (forklift) ឬរទេះរុញ (dolly) ដើម្បីផ្លាស់ប្តូរកន្លែងផលិតផល (មួយគំនរៗ)។ ជាទូទៅ កំណាល់ត្រូវបានប្រើក្នុងឃ្លាំងធំៗ ពីព្រោះការទុកដាក់និងចល័តកំណាល់ ត្រូវទុកឲ្យមានចន្លោះ ដើម្បីឲ្យមានខ្យល់ចេញចូល ហើយត្រូវរក្សាឱសថ និងផលិតផលសុខាភិបាលឲ្យផុតពីកម្រាលឥដ្ឋ ។

ប្រសិនបើប្រើកំណាល់ក្នុងឃ្លាំងត្រូវ ៖

- ពិនិត្យមើលកំណាល់មុនពេលដាក់ឱសថ និងផលិតផលសុខាភិបាលពីលើ។ ត្រូវប្រាកដថាកំណាល់ត្រូវរឹងមាំ មិនរង្គោះរង្គើ បែក ឬបាក់ ព្រមទាំងមិនមានលៀនដែកគោលចេញ។ កំណាល់ដែលមិនរឹងមាំអាចបាក់ អំឡុងពេលលើកឡើងចុះ និងបង្កឲ្យមានរបួសដល់អ្នកលើក ព្រមទាំងបណ្តាលឲ្យខូចផលិតផល។
- គរកំណាល់ទទេឲ្យមានរបៀបរៀបរយ និងឆ្ងាយពីច្រកដើរ
- ប្រសិនបើអាច គួរទុកកំណាល់ក្នុងបន្ទប់ និងឲ្យឆ្ងាយពីសារធាតុដែលអាចធ្វើឲ្យខូចឈើកំណាល់ ។

ដោយមិនគិតពីវត្ថុធាតុដែលយកមកធ្វើកំណាល់ ដែលអាចបង្កើនហានិភ័យនៃអគ្គីភ័យ ពីព្រោះកំណាល់មាន ចន្លោះឬប្រហោងដែលចរន្តខ្យល់អុកស៊ីហ្សែនចេញចូលបាន អាចបង្កឲ្យមានអគ្គីភ័យ។ ត្រូវអនុវត្តការប្រុងប្រយ័ត្នដើម្បីសុវត្ថិភាពដែលនឹងបកស្រាយនៅក្នុងផ្នែកនៃគោលការណ៍នេះ។

ធ្នើរ ទូ តុ និងកំណាល់ អាចធ្វើពីឈើ លោហៈ និងប្លាស្ទិក។ ធ្នើរ ទូ និងកំណាល់ដែលធ្វើពីលោហៈ អាចជាដែកថែប (steel) ដែកថែបអត់ច្រេះ(stainless steel) ឬអាលុយមីនីញ៉ូម។ សម្ភារៈដែលធ្វើពីលោហៈមានតម្លៃថ្លៃ ប៉ុន្តែរឹងមាំជាប់បានយូរ និងមិនងាយឆេះ បើប្រៀបធៀបនឹងសម្ភារៈដែលធ្វើពីប្លាស្ទិក ឬឈើ។ សម្ភារៈដែលធ្វើពីលោហៈ មិនមានបញ្ហាជាមួយសត្វល្អិត សត្វកកេរ ឬពពួកផ្សិត ។

**រថយន្តលើក និងរទេះលើកកំណាល់**

ប្រសិនបើមានផែនការប្រើរថយន្តលើក ឬរទេះលើកកំណាល់ក្នុងឃ្លាំង ៖

- កម្រាលឥដ្ឋត្រូវរាបស្មើ និងអាចធន់នឹងទម្ងន់របស់រថយន្តលើក
- ធានាឲ្យមានកន្លែងគ្រប់គ្រាន់ក្នុងឃ្លាំង សម្រាប់រថយន្តឬរទេះលើកដាក់ផលិតផល
- ត្រូវពិចារណាពីទំហំរថយន្ត ឬរទេះលើកឲ្យសមស្របនឹងទំហំឃ្លាំង។ រថយន្តនិងរទេះលើកអាចមានប្រើ ឧស្ម័ន ប្រេងម៉ាស៊ូត ប្រេងសាំង ឬអគ្គីសនី ទាំងអស់នេះប៉ះពាល់ដល់កំលាំង (Capacity) និងតម្លៃរបស់រថយន្ត ឬរទេះលើក ។ គួរពិចារណាផងដែរ អំពីខ្យល់ចេញចូលក្នុងឃ្លាំង និងបរិស្ថានជុំវិញ ។
- រក្សាឲ្យមានអាគុយបំរុង ឬប្រដាប់សាកអាគុយ បើចាំបាច់ ហើយត្រូវធានាអាចប្រើបានពេញ ១ ថ្ងៃ
- រថយន្តឬរទេះលើកត្រូវតែលើកដល់ធ្នើរខ្ពស់បំផុត
- រក្សាកំណត់ត្រាថែទាំ និងសេវា នៅកន្លែងសុវត្ថិភាព និងកន្លែងមើលឃើញ
- រក្សានិងបិទប្រកាសអត្តសញ្ញាណបុគ្គលិកដែលបានបណ្តុះបណ្តាល និងដែលបានអនុញ្ញាតឲ្យប្រើឬបើករថយន្ត ឬរទេះលើក ។

រថយន្តឬរទេះលើកមានពីរប្រភេទ គឺប្រភេទដើរបញ្ជា (*walkie*) និងប្រភេទអង្គុយបញ្ជា (*seated*) ហើយប្រភេទនីមួយៗមានអត្ថប្រយោជន៍រៀងៗខ្លួន។ ប្រភេទដើរបញ្ជាគឺល្អជាងគេ ពីព្រោះអាចបត់បែនតាមចន្លោះតូចដោយ សារកាំរបត់តូច(ងាយស្រួលបត់ចុះឡើង) ប៉ុន្តែមានចលនាយឺតយ៉ាវណាស់ ហើយមិនមានប្រយោជន៍សម្រាប់ ប្រើនៅក្នុងឃ្លាំងធំ។ ប្រភេទអង្គុយបញ្ជា មានចលនាលឿនជាង និងមានតម្លៃថ្លៃផងដែរ។

### ៣.៣. សារធាតុងាយឆេះ

- សារធាតុងាយឆេះដែលឃើញមាននៅក្នុងឃ្លាំងឱសថ និងផលិតផលសុខាភិបាល រួមមាន acetone, anesthetic ether, alcohol (មុនពង្រាវ) និង ប្រេងកាត ។
- ចំពោះការរៀបចំទុកដាក់សារធាតុងាយឆេះក្នុងបរិមាណច្រើន ត្រូវទុកនៅកន្លែងដាច់ដោយឡែកពីឃ្លាំងធំ និង មានចម្ងាយមិនតិចជាងពី២០ម៉ែត្រពីអគារដទៃទៀត ហើយត្រូវមានឧបករណ៍ពន្លត់អគ្គីភ័យ ។ ផលិតផលងាយឆេះដែលមានបរិមាណច្រើន មិនត្រូវទុកដាក់នៅកន្លែងស្តុកឱសថ និងផលិតផលសុខាភិបាលឡើយ ។
- សារធាតុងាយឆេះដែលមានបរិមាណតិចអាចរក្សាទុកក្នុងទូសុវត្ថិភាព ដែលមានខ្យល់ចេញចូលឆ្ងាយពីអណ្តាតភ្លើង និងពីកន្លែងភ្ជាប់ចរន្តអគ្គីសនី។ ដាក់សញ្ញាសំគាល់នៅខាងក្រៅទូដែកអំពីសារធាតុងាយឆេះ និងបិទសញ្ញាអន្តរជាតិអំពីគ្រោះថ្នាក់។ បន្ថែមលើនេះ ធ្នើរនៃទូដែកនីមួយៗត្រូវតែធ្វើឡើង យ៉ាងណាដើម្បីការពារពីការកំពប់សារធាតុ។ ត្រូវតែទុកដាក់សារធាតុងាយឆេះក្នុងសម្ភារៈស្តុកដើមរបស់វា។
- សារធាតុរាវងាយឆេះនីមួយៗមានសរសេចំណុចនៃចំហាយឆេះ (flash point) ។ ចំណុចនៃចំហាយឆេះ (flash point) គឺជាចំណុចនៃសីតុណ្ហភាពទាបបំផុតដែលធ្វើឲ្យអង្គធាតុរាវងាយឆេះទាំងអស់អាចភាយ ក្នុងបរិមាណគ្រប់គ្រាន់ និងអាចឆេះបាននៅក្នុងបរិយាកាសជុំវិញសារធាតុទាំងនោះ។ ចំណុចនៃចំហាយឆេះ (flash point) បង្ហាញអំពីចំណុចនៃភាពងាយឆេះ។
  - ❖ សារធាតុ Acetone និង Anesthetic ether មានចំណុចនៃចំហាយឆេះ (flash point) គឺ -18◦c
  - ❖ អាល់កុលសុទ្ធមានចំណុចនៃចំហាយឆេះ (flash point) គឺ 18 ◦c ទៅ 23 ◦c
  - ❖ សារធាតុប្រេងកាត (kerosene) មានចំណុចនៃចំហាយឆេះ (flash point) គឺ 23◦c ទៅ 61◦c
- មិនចាំបាច់ទុកដាក់សារធាតុងាយឆេះ នៅសីតុណ្ហភាពក្រោមចំណុចនៃចំហាយឆេះ (flash point) ឡើយ ប៉ុន្តែចាំបាច់ត្រូវស្តុកនៅកន្លែងត្រជាក់ខ្លាំងបើអាចធ្វើបាន និងត្រូវជៀសវាងប៉ះផ្ទាល់នឹងពន្លឺថ្ងៃ។ ការត្រួតពិនិត្យអត្រាភាយរបស់សារធាតុ គឺជាការចាំបាច់ដើម្បីបញ្ចៀសការកើនសម្ពាធ ។

### ៣.៤. សារធាតុកាត់

- សារធាតុកាត់ឬអុកស៊ីតករ ដែលតែងតែជួបប្រទះនៅក្នុងមន្ទីរពេទ្យឬមូលដ្ឋានសុខាភិបាលដទៃទៀត រួមមាន trichloracetic acid, glacial acetic acid, concentrated ammonia solutions, silver nitrate, sodium nitrate, និង sodium hydroxide pellets ។
- សារធាតុកាត់ (corrosive substances) ត្រូវតែទុកដាក់ដាច់ឆ្ងាយពីសារធាតុងាយឆេះ (flammables) ពោលគឺត្រូវដាក់ដាច់ដោយឡែកក្នុងទូសុវត្ថិភាព ដើម្បីបង្ការការលេចធ្លាយ។ ត្រូវប្រើស្រោមដៃ និងវ៉ែនតាដែលជាប្រភេទប្រើក្នុងឧស្សាហកម្ម នៅពេលប្រើប្រាស់សារធាតុកាត់ទាំងអស់នេះ។

## ៤. ការរក្សាគុណភាពឱសថ និងផលិតផលសុខាភិបាល

### ៤.១. ការត្រួតពិនិត្យគុណភាពឱសថនិងផលិតផលសុខាភិបាល

ឱសថ និងផលិតផលសុខាភិបាលមានប្រភេទខុសៗគ្នា ការខូចខាត ឬបែកបាក់ក៏ខុសៗគ្នាដែរ។ សូចនាករមួយចំនួនអាចប្រើដើម្បីរកការខូចខាត ឬបែកបាក់មានដូចខាងក្រោម ៖

**ផលិតផលទាំងអស់**

- ការវេចខ្ចប់រហែក ឬបែកបាក់ (ដូចជា កូនដប ដប ប្រអប់ ។ល។)
- ការបាត់បង់ ចំនួនមិនគ្រប់(ក្នុងប្រអប់ឬដប) ស្លាកសញ្ញាមិនអាចអានបាន ។

**ផលិតផលរាវ**

- ប្រែពណ៌
- ឡើងអ័ព្ទ
- ឡើងកករ
- ដាច់គម្របដប
- បែកអំពូល ដប ឬ កូនដប
- សើម ឬមានសំណើមលើកញ្ចប់

**ឱសថសម្រាប់ចាក់**

- ឱសថសម្រាប់ចាក់មិនត្រូវមានកករបន្ទាប់ពីក្រឡុករួច

**ផលិតផលមានជាតិរំអិល** (Lubricated latex products)

- កញ្ចប់ស្អិត
- ផលិតផលប្រែពណ៌ឬមានជាតិរំអិល
- កេសឬប្រអប់ប្រឡាក់
- លេចប្រេង (ភាគច្រើនសើមកញ្ចប់)

**ការវេចខ្ចប់ដោយសន្លឹកស្តើង (សន្លឹកអាលុយមីញ៉ូម)**

- កញ្ចប់មានរន្ធឬស្នាមធ្លុះ

**ឱសថកាប់ស៊ុល**

- ប្រែពណ៌
- ស្អិត
- កំពិតឬបែកកាប់ស៊ុល

**ផលិតផលគ្រាប់**

- ប្រែពណ៌
- បែកបាក់
- បាត់គ្រាប់ (ដូចជាបាត់ពីបន្ទះ)
- ស្អិត (ពិសេសឱសថស្រោប)
- ក្លិនខុសពីធម្មតា

**ផលិតផលដែលងាយខូចនឹងពន្លឺ (ហ្វីលថតកាំរស្មី X )**

- កញ្ចប់រហែក ឬហៀរទឹក (អង្គធាតុរាវ)

**ឱសថដាក់ក្នុងបំពង់** (tube)

- បំពង់ស្អិតជាប់គ្នា
- លេចឱសថ

- បំពង់មានរន្ធ ឬស្នាមធ្លុះ

**ផលិតផលគ្មានមេរោគ (រួមទាំងកងដាក់ក្នុងស្បូន)**

- កញ្ចប់រហែក ឬហៀរទឹក
- បាត់ផ្នែកខ្លះ
- បែកបាក់ ឬប្រែប្រួលរូបរាង
- មានសំណើមនៅខាងក្នុងកញ្ចប់
- កញ្ចប់ប្រឡាក់

**ផលិតផលជ័រ**

- ស្អិត
- ស្រួយ
- បែកបាក់

**ប្រតិករ**

- ប្រែពណ៌

- មិនត្រូវផ្តល់ផលិតផលខូចគុណភាព ឲ្យមូលដ្ឋានសុខាភិបាលឬឲ្យអតិថិជនឡើយ។ ប្រសិនបើមិនប្រាកដថា ផលិតផលខូចគុណភាពណាមួយ ត្រូវពិនិត្យមើលជាមួយអ្នកដែលយល់ដឹង។ ហាមផ្តល់ ឬចែកចាយផលិតផលណាដែលសង្ស័យថាខូចគុណភាព។
- រាយការណ៍អំពីផលិតផលដែលមានបញ្ហា និងបង្វែរផលិតផលនោះទៅឲ្យអង្គភាពដើមវិញ (ពេលប្រគល់-ទទួលសម្រាប់សេវាសាធារណៈ)។

| |
|---|
| *ហាមបញ្ចេញ ឬចែកចាយផលិតផលដែលសង្ស័យថាខូចគុណភាព* |

## ៤.២. ផលិតផលដែលបានបញ្ជូនត្រឡប់វិញ និងការប្រមូលមកវិញ

ផលិតផលដែលបានបញ្ជូនត្រឡប់វិញ ឬមិនទទួល រួមទាំងផលិតផលដែលបានប្រមូលមកវិញ ត្រូវអនុវត្តទៅតាមនីតិវិធីដែលមាន និងត្រូវរក្សាទុកឯកសារដែលបានកត់ត្រា។

ផលិតផលដែលត្រូវបញ្ជូនត្រឡប់ទាំងអស់ ត្រូវរក្សាទុកនៅកន្លែងរង់ចាំ (Quarantine) ហើយត្រូវបញ្ជូនទៅវាយតម្លៃគុណភាព រួចបញ្ចូលឃ្លាំង សម្រាប់ទុកប្រើប្រាស់ចំពោះផលិតផលណាដែលរកឃើញថាមានគុណភាពល្អ។

## ៤.៣. ការត្រួតពិនិត្យសីតុណ្ហភាព

### ក. សំណើមបរិយាកាស

នៅពេលស្លាកសញ្ញាសរសេរថា «ការពារសំណើម» រក្សាទុកដាក់ផលិតផលក្នុងសំណើមបរិយាកាសមិនឲ្យលើសពី ៦០%។ ដើម្បីបន្ថយក្តីកង្វល់អំពីសំណើម ៖

- **ចរន្តខ្យល់ចេញចូល ៖** បើកបង្អួច ឬរន្ធខ្យល់របស់ឃ្លាំង ដើម្បីឲ្យមានចរន្តខ្យល់ចេញចូល។ ត្រូវធានាឲ្យបង្អួចមានសំណាញ់ការពារសត្វល្អិតឬសត្វស្លាប និងមានរបារ ឬមិនត្រូវបើកបង្អួចឲ្យសត្វល្អិតទុំលើប្រអប់ ផលិតផល ដាក់ប្រអប់ផលិតផលលើកំណល់ និងធានាឲ្យមានចន្លោះរវាងកំណល់ និងជញ្ជាំងឃ្លាំង។
- **ការវេចខ្ចប់ ៖** ធានាឲ្យគម្របទាំងអស់បិទជិត និងមិនត្រូវបើកឧបករណ៍វេចខ្ចប់ថ្មី បើមិនចាំបាច់។

- **ចរាចរខ្យល់៖** ប្រើកង្ហារបក់ខ្យល់ចេញចូល។ នៅក្នុងឃ្លាំងធំ ត្រូវប្រើកង្ហារពិដាន និងចំពោះឃ្លាំងតូច ត្រូវប្រើកង្ហារឈរ ។
- **ម៉ាស៊ីនត្រជាក់ ៖** ត្រូវប្រើម៉ាស៊ីនត្រជាក់ តែការប្រើម៉ាស៊ីនត្រជាក់ មានតម្លៃថ្លៃ និងអាស្រ័យលើចរន្តអគ្គីសនីព្រមទាំងតម្រូវឲ្យមានការថែទាំជាប្រចាំ។ ការប្រើឧបករណ៍បន្ថយសំណើមអាចជាជម្រើសមួយដែលមានតម្លៃថោកទាក់ទងទៅនឹងលក្ខខណ្ឌអាកាសធាតុ។ ការប្រើឧបករណ៍ទាំងនេះ តម្រូវឲ្យមានចរន្តអគ្គីសនី និងតម្រូវមិនអោយមានទឹកនៅក្នុងឃ្លាំង ។

**ខ. ពន្លឺថ្ងៃ**

ឱសថនិងផលិតផលសុខាភិបាលមួយចំនួន ងាយខូចជាមួយនឹងពន្លឺថ្ងៃ និងអាចខូចពេលប៉ះនឹងពន្លឺថ្ងៃ។ ផលិតផលទាំងនោះរួមមានឱសថ Multiple vitamins, Furosemide, ឱសថ Chlorpheniramine maleate, ឱសថ Hydrocortisone, ផលិតផលធ្វើពីជ័ររុក្ខជាតិ (ដូចជាស្រោមអនាម័យសម្រាប់បុរស) និងហ្វីលកាំរស្មីអេច (X-ray) ។

ការការពារផលិតផលពីពន្លឺថ្ងៃ ៖

- បាំងបង្អួច ឬប្រើវាំងនន បើសិនបង្អួចចាំងពន្លឺថ្ងៃមកចំ។
- ទុកផលិតផលក្នុងកេស ។
- កុំទុកដាក់ផលិតផលក្រោមពន្លឺថ្ងៃ។
- ដាក់ផលិតផលក្នុងកែវស្រអាប់ ឬកែវពណ៌ាងងឹតតាមតម្រូវការរបស់ផលិតផលទាំងនោះ។
- រក្សាឲ្យមានដើមឈើនៅបរិវេណជុំវិញឃ្លាំងដើម្បីឲ្យមានម្លប់ ប៉ុន្តែត្រូវពិនិត្យមើលដើមឈើទាំងនោះជាប្រចាំដើម្បី កុំឲ្យមានមែកណាមួយមកប៉ះអគារដែលអាចធ្វើឲ្យខូចខាតឃ្លាំង។

**គ. កំដៅ**

ចូរចាំថាកំដៅអាចធ្វើឲ្យខូចផលិតផលបាន។ កំដៅធ្វើឲ្យរលាយប៉ូម៉ាត (Ointments) និងគ្រីម (Creams) ព្រមទាំងធ្វើឲ្យផលិតផលដទៃទៀតប្រើលែងកើត។ អនុវត្តតាមគោលការណ៍ណែនាំ ដែលថែងអំពីការការពារផលិតផលពីសំណើម និងពីពន្លឺថ្ងៃ ក៏នឹងអាចជួយការពារផលិតផលពីកំដៅផងដែរ។ ជាការចាំបាច់ដែលតម្រូវឲ្យមានសីតុណ្ហមាត្រនៅក្នុងឃ្លាំង ដើម្បីតាមដានសីតុណ្ហភាព (ចូរមើលផ្នែកស្តីពីការតាមដាន សីតុណ្ហភាព)។

**ឃ. ការត្រួតពិនិត្យតាមដាន**

ត្រួតពិនិត្យតាមដានសីតុណ្ហភាពនៅកន្លែងខុសៗគ្នាក្នុងឃ្លាំងជាប្រចាំ។

- ដាក់សីតុណ្ហមាត្រនៅកន្លែងខុសៗគ្នាក្នុងឃ្លាំង សម្រាប់ត្រួតពិនិត្យតាមដានកំដៅ។
- រក្សាឲ្យមានខ្យល់ចេញចូលក្នុងឃ្លាំងបានល្អ (ចូរមើលផ្នែកស្តីពីសំណើម)។ ដើម្បីឲ្យមានខ្យល់ចេញចូល ត្រូវដាក់ កេសឱសថនិងផលិតផលសុខាភិបាលលើកំណល់ និងរៀបជាជួរដោយមានទុកចន្លោះនៅក្នុងឃ្លាំង (ចូរមើលផ្នែកស្តីពី ការរៀបចំផលិតផល)។
- បញ្ចៀសពន្លឺថ្ងៃចាំងចូលឃ្លាំងដោយផ្ទាល់។

**ង. ទូទឹកកក និងទូបង្កក**

- ទូទឹកកកដែលបើកពីលើគឺល្អជាងទូទឹកកកបញ្ឈរ ពីព្រោះខ្យល់ក្តៅភាយឡើងលើពេលខ្យល់ត្រជាក់ចុះក្រោម
- ផ្នែកត្រជាក់បំផុតនៃទូទឹកកកបញ្ឈរគឺនៅបាតក្រោម
- ទុកដាក់ផលិតផលដែលងាយកកឬកកនៅសីតុណ្ហភាពទាប នៅធ្នើរខាងលើនៃទូទឹកកក
- ត្រូវមានកញ្ចប់ទឹកកកគ្រប់គ្រាន់ ដើម្បីដាក់ក្នុងប្រអប់ត្រជាក់ សម្រាប់ធ្វើឲ្យត្រជាក់ផលិតផលណាដែលតម្រូវឲ្យ ដាក់ក្នុងលក្ខខណ្ឌត្រជាក់ពេលដឹកជញ្ជូន និងមិនត្រូវប្រើកញ្ចប់ទឹកកកណាដែល

មានច្រកអង្គធាតុរាវដទៃទៀត ដែលមានពណ៌ខៀវឬបៃតង។ ពេលរៀបចំឧបករណ៍ប្រព័ន្ធត្រជាក់ចំពោះឃ្លាំងធំ ត្រូវប៉ាន់ប្រមាណអំពីតម្រូវការ កញ្ចប់ទឹកកក និងទីកន្លែងក្នុងទូបង្កកទឹក។

- ប្រសិនបើមានកន្លែងគ្រប់គ្រាន់ ត្រូវដាក់ដបទឹកធ្វើពីប្លាស្ទិកមួយចំនួនបន្ថែមក្នុងទូទឹកកក។ ការដាក់ដបទឹកនេះ អាចជួយរក្សាសីតុណ្ហភាពត្រជាក់បានយូរ ពេលដាច់ចរន្តអគ្គីសនី ។
- ដាក់ទូទឹកកក និងទូត្រជាក់នៅចន្លោះពីជញ្ជាំងប្រហែល ២០ ទៅ ៤០សង់ទីម៉ែត្រ ។ ការដាក់របៀបនេះ នឹងបង្កើនចរន្តខ្យល់ចេញចូល។
- តាមលក្ខខណ្ឌតម្រូវ បន្ទប់ដែលមានទូទឹកកកនិង/ឬទូបង្កកច្រើន ត្រូវមានម៉ាស៊ីនត្រជាក់។ ទូទឹកកក និងទូបង្កក បង្កើតឲ្យមានកំដៅច្រើនក្នុងបន្ទប់ ហើយកំដៅទាំងនេះអាចបណ្ដាលឲ្យខូចទូទឹកកកនិងទូបង្កកនោះពេលប្រើរយៈពេលយូរ។
- ប្រសិនបើមិនមានម៉ាស៊ីនត្រជាក់ ត្រូវដាក់កង្ហារជុំវិញឧបករណ៍ដើម្បីបង្កើនលំហូរខ្យល់។ ពេលដាក់កង្ហារ ត្រូវដាក់យ៉ាងណាឲ្យមានខ្យល់បក់ពីក្រោយទូទឹកកក។
- ជាការល្អ ចំពោះឃ្លាំងធំគួរមានបន្ទប់ត្រជាក់មួយ ប្រសើរជាងប្រើទូទឹកកកច្រើន។

**ច. ការផ្គត់ផ្គង់ថាមពលអគ្គិសនី**

ពេលប្រភពចរន្តអគ្គីសនី មិនអាចផ្ដល់ថាមពលបានជាប់លាប់ ត្រូវរៀបចំបំពាក់ឧបករណ៍អគ្គីសនីដែលប្រើដោយថាមពលព្រះអាទិត្យ ឬផ្គត់ផ្គង់អគ្គីសនីតាមប្រភពផ្សេងៗទៀត ដើម្បីធ្វើឲ្យឃ្លាំងត្រជាក់ និងប្រើទូទឹកកកបាន ។ ប្រសិនបើ ពុំមានប្រភពថាមពលអគ្គិសនីដោយពន្លឺព្រះអាទិត្យ ត្រូវមានប្រេងសម្រាប់ប្រើម៉ាស៊ីនភ្លើង ឲ្យបានគ្រប់គ្រាន់ដើម្បីដំណើរការម៉ាស៊ីនឲ្យបានពីរឬបីថ្ងៃ (ចូរមើលផ្នែកស្ដីពីស្តុកសារធាតុដែលងាយឆេះ)។ ត្រូវដំណើរការ ម៉ាស៊ីនភ្លើងមួយខែមួយដងឲ្យបានទៀងទាត់ ដើម្បីធានាថាម៉ាស៊ីនភ្លើងនៅតែដំណើរការធម្មតា។ ចំពោះឃ្លាំងធំ អាចចុះកិច្ចសន្យាជាមួយអ្នកម៉ៅការ ដើម្បីថែទាំម៉ាស៊ីនភ្លើង និងប្រព័ន្ធអគ្គីសនី។

ប្រសិនបើការផ្គត់ផ្គង់ចរន្តអគ្គីសនីមិនជាប់លាប់ ចូរប្រើទូទឹកកកដែលប្រើថាមពលព្រះអាទិត្យ ឬឧស្ម័ន។

**ឆ. លក្ខខណ្ឌរួមក្នុងការទុកដាក់**

លក្ខខណ្ឌដូចខាងក្រោមទាក់ទងនឹងការតម្រូវសីតុណ្ហភាព និងការផ្គត់ផ្គង់ឱសថនិងផលិតផលសុខាភិបាល។ ការអនុវត្តន៍តាមលក្ខខណ្ឌក្នុងការរក្សាទុកដាក់របស់រោងចក្រផលិត ដែលបញ្ជាក់លើសំបកប្រអប់ផលិតផល គឺមានសារៈសំខាន់ណាស់។

- **ការទុកដាក់នៅកន្លែងកក ៖** ឱសថនិងផលិតផលសុខាភិបាលមួយចំនួន ដូចជាវ៉ាក់សាំងពេលដឹកជញ្ជូនតម្រូវឲ្យរក្សាក្នុងប្រព័ន្ធត្រជាក់គឺនៅក្នុងកម្រិតសីតុណ្ហភាព -២០ អង្សាសេ ។ ការទុកដាក់ផលិតផលនៅកន្លែងកក គឺជាការធម្មតាសម្រាប់ទុកដាក់រយៈពេលយូរនៅឃ្លាំងធំ ។
- **ការទុកដាក់នៅសីតុណ្ហភាពពី ២ ទៅ ៨ អង្សាសេ ៖** ឱសថនិង ផលិតផលសុខាភិបាលមួយចំនួន គឺងាយខូចនឹងកំដៅយ៉ាងខ្លាំង ប៉ុន្តែក៏មិនត្រូវការត្រជាក់ដល់កកដែរ។ ជាធម្មតាផលិតផលទាំងនេះត្រូវដាក់ក្នុងផ្នែកទី១ និងទី២ នៃទូទឹកកក(កុំដាក់ក្នុងកន្លែងកក)។ សីតុណ្ហភាពនៃផ្នែកទាំង២នេះ សមស្របនឹងទុកដាក់វ៉ាក់សាំងរយៈពេលខ្លី។
- **ទុកដាក់នៅកន្លែងត្រជាក់ ៖** ឱសថនិងផលិតផលសុខាភិបាលមួយចំនួន ត្រូវស្តុកនៅសីតុណ្ហភាពពី ៨ ទៅ ១៥ អង្សាសេ។
- **ទុកដាក់នៅសីតុណ្ហភាពបន្ទប់ម៉ាស៊ីនត្រជាក់ ៖**ឱសថនិង ផលិតផលសុខាភិបាលមួយចំនួន ត្រូវស្តុកនៅសីតុណ្ហភាពពី ១៥ ទៅ ២៥ អង្សាសេ។

- **ទុកដាក់នៅសីតុណ្ហភាពបរិយាកាស(បន្ទប់)៖** ទុកដាក់នៅសីតុណ្ហភាពនៃបរិយាកាសធម្មតា។ លក្ខខណ្ឌនេះមិនសូវប្រើទូលំទូលាយទេ ដោយសារសីតុណ្ហភាពបរិយាកាសជុំវិញតែងមានការប្រែប្រួលជានិច្ច។ សីតុណ្ហភាពបន្ទប់ ឬសីតុណ្ហភាពនៃលក្ខខណ្ឌធម្មតា មានន័យថាការទុកដាក់ក្នុងបន្ទប់ដែលមានបរិយាកាសស្ងួតមានខ្យល់បក់ចេញចូល និងមានសីតុណ្ហភាពពី ១៥ ទៅ ២៥ អង្សាសេ ឬឡើងដល់ ៣០ អង្សាសេ អាស្រ័យលើលក្ខខណ្ឌអាកាសធាតុ។

**ឱសថនិងផលិតផលសុខាភិបាលដែលមានបញ្ហាស្ថិរភាពគុណភាពក្នុងស្ថានភាពអាកាសធាតុត្រូពិច ៖**

**ឱសថគ្រាប់សម្រាប់លេប** (សណ្ឋានរឹង)

- Acetylsalicylic acid
- Amoxicillin
- Ampicillin
- Penicillin V

**ឱសថស៊ីរ៉ូ (សណ្ឋានរាវ)**

- ស៊ីរ៉ូ Paracetamol

**ឱសថសម្រាប់ចាក់**

- Ergometrine
- Methylergometrine
- Adrenaline
- Reconstituted antibiotic
- Oxytocin

***អនុវត្តទៅតាមសេចក្តីណែនាំរបស់រោងចក្រផលិត***

***ក្នុងការរៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាល***

### ៤.៤. បង្ការការខូចគុណភាព និងការចម្លងសារធាតុផ្សេងៗ

**ក. ការបែកបាក់**

ត្រូវជៀសវាងរៀបចំទុកដាក់ផលិតផលដែលមានបរិមាណច្រើននាំឲ្យបែកបាក់។ ផលិតផលមិនត្រូវដាក់គរលើគ្នាមាន កំពស់លើសពី ២,៥ម៉ែត្រ (តាមវិធានទូទៅ)។ ផលិតផលណាដែលធ្ងន់ ឬងាយបែក (ដូចជា ឱសថច្រកដបកែវជាដើម) ត្រូវរៀបជាគំនរតូចៗ។ សម្ភារៈដែលមានជ្រុងស្រួចត្រូវរុំ ឬវេចខ្ចប់ឲ្យជិត។ ការសំខាន់គឺត្រូវធានាថា ពេលរៀបចំទុកដាក់ផលិតផលធ្វើយ៉ាងណាកុំឲ្យមានធ្លាក់ ឬរបួសដល់បុគ្គលិកឃ្លាំង។

**ខ. ធូលី**

បិទកាលវិភាគ និងសេចក្តីណែនាំពីការសម្អាតឃ្លាំង និងបរិវេណជុំវិញ។ បោស ជូត ឬដុសលាងកម្រាលឥដ្ឋឲ្យបានទៀងទាត់។ ជូតសម្អាតធ្នើរ និងសម្អាតធូលីពីផលិតផល។ បញ្ចេញសម្រាមឬសំណល់ដោយធ្វើយ៉ាងណា បញ្ចៀសកុំឲ្យមានសត្វចង្រៃ រើ កកាយ ហើយត្រូវដាក់សម្រាមក្នុងធុងបិទជិត។

**គ. ហេដ្ឋារចនាសម្ព័ន្ធ**

ត្រូវធានាថាឃ្លាំងមានប្រភពទឹកដើម្បីសម្អាត។ បើគ្មានបំពង់ទឹកមកដល់ ត្រូវបង្កើតប្រព័ន្ធទឹក ដោយដាក់ធុងចំណុះ ២០០លីត្រ លើទម្រខ្ពស់ហើយភ្ជាប់បំពង់ទឹកមកដល់បរិវេណឃ្លាំង ឬសាងសង់ប្រព័ន្ធទឹកថ្មី ដោយតភ្ជាប់ពីប្រភពទឹកណាមួយមកឃ្លាំង។

**ឃ. សារធាតុសម្អាត**

ត្រូវមានថវិកាដើម្បីទិញសារធាតុសម្អាត។ ប្រើសារធាតុសាប៊ូសម្រាប់សម្អាតរោងចក្រ (industrial detergent) បើអាចរកបាន ជាពិសេសចំពោះឃ្លាំងធំ ទោះបីជាសាប៊ូទាំងនោះនាំចូលពីក្រៅប្រទេសនិងមានតម្លៃថ្លៃក្តី។ ព្យាយាមប្រើសារធាតុសាប៊ូដែលមានក្នុងស្រុក ជាពិសេសចំពោះឃ្លាំងតូច ឬឃ្លាំងនៅតំបន់ដាច់ស្រយ៉ាល។ ត្រូវសម្អាតឃ្លាំងឲ្យបានទៀងទាត់ដោយប្រើសារធាតុក្លរ ដែលជាសារធាតុធ្វើឲ្យស (chlorine bleach ) ឧទាហរណ៍ មួយខែម្តង។

**ង. បរិវេណខាងក្រៅឃ្លាំង៖** ប្រមូលសម្រាមពីសួនច្បារ និងសំបកកេសហើយដុត ប្រសិនបើពុំមានភ្នាក់ងារប្រមូលសម្រាម។ ត្រូវប្រុងប្រយ័ត្នភ្លើងពេលកំពុងដុតសម្រាម និងកុំដុតក្បែរអគារ ហើយត្រូវដឹងច្បាស់ថា មិនមានខ្យល់បក់មកប៉ះអគារ។

## ៤.៥. ការការពារសត្វចង្រៃ

### ក. ការបង្ការផ្នែកខាងក្នុងឃ្លាំង

- រៀបចំឬកែសម្រួលបន្ទប់ឃ្លាំងឲ្យងាយស្រួលជូតសម្អាត និងការពារសំណើម។
- រក្សាបរិស្ថានឲ្យស្អាតជានិច្ច ដើម្បីបង្ការកុំឲ្យមានសត្វចង្រៃនៅ។ ឧទាហរណ៍៖ ការទុកសំណល់គឺត្រូវទុក ក្នុងធុង បិទគម្របជិត ហើយត្រូវសម្អាតកម្រាលឥដ្ឋ និងធ្នើរជាប្រចាំ។
- ហាមទុកចំណីអាហារក្នុងឃ្លាំង។
- រក្សាផ្នែកខាងក្នុងឃ្លាំងឲ្យបានស្ងួតល្អ។
- លាបថ្នាំឬលាបវ៉ែកនីលើឈើឲ្យបានស្អាត តាមលក្ខខណ្ឌតម្រូវ។
- ប្រើកំណល់ និងធ្នើរ។
- បង្ការកុំឲ្យសត្វចង្រៃចូលឃ្លាំង។
- ពិនិត្យមើលឃ្លាំងជាប្រចាំ រកមើលសត្វចង្រៃចូល។
- ការវេចខ្ចប់និងការបញ្ជូនចេញត្រូវពិនិត្យមើលកេស ដើម្បីធានាកុំឲ្យមានសត្វចង្រៃ។ ឧទាហរណ៍៖ កេសអាច ខ្ចប់ឡើងវិញ ឬដាក់សារធាតុបឺតសំណើម (Dehydrating agent) បើចាំបាច់។

### ខ. ការបង្ការផ្នែកខាងក្រៅឃ្លាំង

- ពិនិត្យ និងសម្អាតឲ្យបានទៀងទាត់នៅបរិវេណខាងក្រៅនៃឃ្លាំង ពិសេសកន្លែងដាក់កាកសំណល់។ រកមើល រូងសត្វកកេរ និងធានាថាសម្រាម និងកាកសំណល់ដទៃទៀតត្រូវបានទុកដាក់ក្នុងធុងបិទគម្របជិត។
- ពិនិត្យមើលថ្លុកទឹកនៅជុំវិញឃ្លាំង និងធានាកុំឲ្យមានធុង កង់ឡានចាស់ៗ ឬវត្ថុដក់ទឹកដទៃទៀត។
- ពិនិត្យមើលគ្រោងឈើនៃតួឃ្លាំង បើឃើញមានរន្ធឬស្នាមប្រេះ ត្រូវផ្សិតដោយប្រើការទឹក (Water sealant)។
- ប្រើអំពូលភ្លើងអគ្គីសនីការពារសត្វចង្រៃបើមាន ហើយដាក់អំពូលភ្លើងអគ្គីសនីនោះ ឲ្យនៅឆ្ងាយពីអាគារឃ្លាំង ដើម្បីកុំឲ្យសត្វចង្រៃរោមឃ្លាំង។

គ. យុទ្ធសាស្ត្រនៃការកំចាត់សត្វចង្រៃ

- **ពួកសត្វកកេរ៖** វិធីសាស្ត្រដោះស្រាយងាយស្រួល សម្រាប់ដោះស្រាយបញ្ហាសត្វកកេរ គឺគ្រាន់តែរាំងសត្វទាំងនោះមិនឲ្យចូល និងរក្សាឃ្លាំងឲ្យនៅស្ងួតនិងស្អាតជានិច្ច។ វិធីផ្សេងទៀតគឺដាក់ឧបករណ៍សម្រាប់ចាប់ ឬដេញសត្វ ដាក់ការស្អិត ដាក់ថ្នាំសម្លាប់សត្វចង្រៃនៅក្នុងឃ្លាំង។

- **សត្វស្លាបឬប្រជៀវ៖** ការបង្ការដ៏ល្អគឺបិទទ្វារនិងបង្អួចឃ្លាំងឲ្យជិត ឬដាក់សំណាញ់ការពារពីខាងក្រៅ។ ត្រូវធានាកុំឲ្យមានរន្ធនៅជញ្ជាំង កម្រាលឥដ្ឋ ពិដាន។ បំពាក់ឧបករណ៍កម្ចាត់សត្វល្អិត (bug zappers...) នៅកន្លែងណា ដែលមានសត្វល្អិត (ឧបករណ៍នេះ ប្រើអំពូលភ្លើងមានកាំរស្មីអ៊ុលត្រាវីយោលេឬហ្លួយអររ៉េសង់)។ ការបំពាក់ឧបករណ៍ទាំងនេះ គឺត្រូវដាក់ឲ្យឆ្ងាយពីផលិតផលសុខាភិបាល ពីព្រោះកាំរស្មីអ៊ុលត្រាវីយោលេ អាចធ្វើឲ្យខូចផលិតផលជាច្រើន ពិសេសផលិតផលធ្វើពីជ័រឈើ ដូចជាស្រោមអនាម័យរបស់បុរស។

- **សត្វស្លាបចង្រៃ ៖** ការបង្ការដ៏ល្អគឺបិទទ្វារ និងបង្អួចឃ្លាំងឲ្យជិត ឬដាក់សំណាញ់ការពារពីខាងក្រៅ។ ត្រូវធានាកុំឲ្យមានរន្ធនៅជញ្ជាំង កម្រាលឥដ្ឋ និងពិដាន។ បំពាក់ឧបករណ៍កម្ចាត់សត្វល្អិត (bug zappers) នៅកន្លែងណាដែលមានសត្វល្អិត (ឧបករណ៍នេះប្រើអំពូលភ្លើងមានកាំរស្មីអ៊ុលត្រាវីយោលេ ឬហ្លួយអររ៉េសង់)។ ការបំពាក់ឧបករណ៍ទាំងនេះគឺត្រូវដាក់ឲ្យឆ្ងាយពីផលិតផលសុខាភិបាល ពីព្រោះកាំរស្មីអ៊ុលត្រាវីយោលេ អាចធ្វើឲ្យខូចផលិតផលជាច្រើន ពិសេសផលិតផលធ្វើពីជ័រឈើ ដូចជាស្រោមអនាម័យរបស់បុរស។

- **សត្វល្មូន ៖** សត្វពស់ភាគច្រើនអាចរារាំងបាន ដោយឧបករណ៍សម្លេង និងសម្អាតសម្រាម ឬស្មៅនៅបរិវេណខាងក្រៅឃ្លាំង។ បើសិនជាមានពស់បង្កបញ្ហាលំបាក ត្រូវសង់របងការពារពស់ជុំវិញឃ្លាំង។ របងគួរធ្វើអំពីសំណាញ់លួសក្រាស់ដោយមានក្រឡាទំហំ ៦មីលីម៉ែត្រ កំពស់ ៩០សង់ទីម៉ែត្រ ដោយកប់ក្នុងដីជម្រៅយ៉ាងតិចពី ១០ ទៅ ១៦សង់ទីម៉ែត្រ។ ផ្នែកខាងលើនៃរបងគួរទ្រេតទៅមុខដោយមានមុំយ៉ាងតិច ៣០ដឺក្រេ និងនៅឆ្ងាយពីឃ្លាំងដោយមានបង្គោលរឹងមាំ។

- **សត្វកណ្ដៀរ ៖** មានវិធីការពាពីរប្រភេទចំពោះសត្វកណ្ដៀរ ប៉ុន្តែវិធីទាំងពីរនោះគឺមានតម្លៃថ្លៃ និងត្រូវការអ្នកជំនាញ។

វិធីទី១ គឺចាក់ថ្នាំកណ្ដៀរចូលក្នុងដីជុំវិញឃ្លាំង បើសិនជាមានបញ្ហាខ្លាំងក្លា បង្កឡើងដោយសត្វកណ្ដៀរ ។

វិធីទី២ កំចាត់កណ្ដៀរផ្សេងទៀត៖

- ប្រើកំដៅដោយដុតសារធាតុមិនពុល ឬសារធាតុរាវនីត្រូហ្សែន
- សង់របាំងលោហៈនៅគ្រឹះក្រោមនៃអាគារឃ្លាំង។បន្ទះស្តើងលោហៈត្រូវសង់ភ្ជាប់ពីគ្រឹះទៅជញ្ជាំងនៃអាគារឃ្លាំង ។ បន្ទះស្តើងត្រូវធ្វើឲ្យកោងទៅមុខដោយបង្កើតជាមុំមួយ ប៉ុន្តែមិនប៉ះនឹងដី។ នៅពេលសត្វកណ្ដៀរ ឬស្រមោចប៉ុនប៉ងឡើងគ្រឹះ ពួកវាត្រូវបានរារាំងដោយរបាលោហៈដែលសាងសង់មិនឲ្យឡើងបាន។
- សង់របាំងដីខ្សាច់ជុំវិញអាគារឃ្លាំងជារបាំងការពារ ប៉ុន្តែគ្រាប់ខ្សាច់ត្រូវមានទំហំពិសេស ហើយវិធីនេះមានតម្លៃថ្លៃ។

## ៥. ការធានាសន្តិសុខ និងសុវត្ថភាព

### ៥.១. ការពារអគ្គិភ័យ

ត្រូវបង្ការកុំឲ្យខូចផលិតផលដោយភ្លើង:

- ត្រូវមានឧបករណ៍ពន្លត់អគ្គីភ័យទៅតាមស្តង់ដារនៅគ្រប់ឃ្លាំង ដោយអនុលោមតាមបទដ្ឋានគតិយុត្តិជាតិ។

- ពិនិត្យមើលឧបករណ៍ពន្លត់អគ្គីភ័យរៀងរាល់ ២ ឬ ៣ខែម្តង ដើម្បីធានាការថែរក្សា និងត្រៀមសម្រាប់ ប្រើប្រាស់។
- សេវាត្រួតពិនិត្យឧបករណ៍ពន្លត់អគ្គីភ័យក្នុងឃ្លាំង ត្រូវធ្វើឡើងយ៉ាងតិចរៀងរាល់១២ខែម្តង
- បំពាក់ឧបករណ៍ត្រួតពិនិត្យផ្សេងក្នុងឃ្លាំង និងពិនិត្យរៀងរាល់២ ឬ៣ខែម្តង ដើម្បីរក្សាគុណភាពប្រើប្រាស់
- ហាមដាច់ខាតការជក់បារីក្នុងឃ្លាំង និងត្រូវបិទស្លាកហាមជក់បារីនៅក្នុងឃ្លាំង។
- បុគ្គលិកឃ្លាំងត្រូវហ្វឹកហាត់ពន្លត់អគ្គីភ័យរាល់ ៦ ខែ ម្តង។
- បិទស្លាកច្រកចេញពេលមានអាសន្ន និងពិនិត្យមើលជាប្រចាំដើម្បីកុំឲ្យមានស្ទះ ឬចេញមិនរួច។
- បំពាក់សញ្ញាប្រុងប្រយ័ត្នអគ្គីភ័យនៅកន្លែងសមស្របក្នុងឃ្លាំង (ពិសេសនៅកន្លែងស្តុកសារធាតុងាយឆេះ)
- ប្រើដីខ្សាច់សម្រាប់ពន្លត់អគ្គីភ័យ នៅទីណាដែលគ្មានឧបករណ៍ពន្លត់អគ្គីភ័យ ដាក់ធុងខ្សាច់នៅក្បែរទ្វារ។

ឧបករណ៍ពន្លត់អគ្គីភ័យមាន៤ប្រភេទ ៖

ឧបករណ៍ពន្លត់អគ្គីភ័យ មានសារធាតុគីមីស្ងួតគឺមានសារធាតុគីមីដូចជា ប៉ូតាស្យូមប៊ីកាបូណាត (ស្រដៀងគ្នា នឹងម្សៅសូដា) និងប្រើឧស្ម័នដែលមានសម្ពាធជាធាតុជំរុញចេញ។ ឧបករណ៍ពន្លត់អគ្គីភ័យទាំងនេះ មានប្រសិទ្ធភាពពន្លត់អគ្គីភ័យបានច្រើនប្រភេទ រួមមានអគ្គីភ័យឆេះអង្គធាតុរឹង មានដូចជា ឈើ ក្រដាស អគ្គីភ័យឆេះអង្គធាតុរាវ មានដូចជា សាំង ប្រេង ខ្លាញ់ និងអគ្គីភ័យឆេះបណ្តាលមកពីអគ្គីសនី។

ឧបករណ៍ពន្លត់អគ្គីភ័យមានទឹកលាយ និងឧស្ម័នដែលមានសម្ពាធប្រើសម្រាប់តែអគ្គីភ័យធម្មតា ដូចជា ឈើ និងក្រដាស។ មិនត្រូវប្រើឧបករណ៍ប្រភេទនេះ សម្រាប់ពន្លត់អគ្គីភ័យដែលបណ្តាលមកពីអង្គធាតុរាវ (ដូចជា សាំង ឬប្រេងឥន្ធនៈ) ឬ អគ្គីភ័យបណ្តាលមកពីអគ្គីសនី។

ឧបករណ៍ពន្លត់អគ្គីភ័យមានឧស្ម័នកាបូនិច ($CO_2$) មានប្រសិទ្ធភាពលើអគ្គីភ័យឆេះអង្គធាតុរាវ (ដូចជា សាំង ឬប្រេងឥន្ធនៈ) និងអគ្គីភ័យបណ្តាលមកពីអគ្គីសនី ប៉ុន្តែមិនមានប្រសិទ្ធភាពលើវត្ថុផ្សេងៗទៀត ដូចជាក្រដាស ទូរ ឬបន្ទះឈើ។ ឧស្ម័នបាញ់ចេញយ៉ាងលឿន និងមិនមានសល់សំណល់គ្រោះថ្នាក់។

ឧបករណ៍ពន្លត់អគ្គីភ័យមានសារធាតុហាលូន(Halon) គឺតែងតែប្រើនៅកន្លែងមានកុំព្យូទ័រ ឬម៉ាស៊ីនដទៃទៀត ពីព្រោះឧបករណ៍ទាំងនេះមិនមានសល់សំណល់។ ឧបករណ៍ប្រភេទនេះប្រើសម្រាប់ពន្លត់អគ្គីភ័យ បណ្តាល មកពីវត្ថុរឹង រាវ និងអគ្គីភ័យបណ្តាលមកពីអគ្គីសនី។ ទោះបីយ៉ាងណាក៏ដោយ សារធាតុហាលូនគឺមានគ្រោះថ្នាក់ពេលដកដង្ហើមចូល និងប៉ះពាល់ដល់បរិស្ថាន។ ឧបករណ៍ទាំងនេះមានប្រសិទ្ធភាពក្នុងបរិយាកាសហាប់ ប៉ុន្តែត្រូវចងចាំថា តំបន់នោះត្រូវធ្វើឲ្យ មានខ្យល់ចេញចូល មុនពេលមនុស្សចេញចូល។

## ៤.២.ការពារការបាត់បង់

### ក. អំឡុងពេលដឹកជញ្ជូន

- ផ្ទៀងផ្ទាត់ឯកសារ។
- ធានាថាកេសផលិតផលត្រូវបានបិទជិតត្រឹមត្រូវ។
- ត្រូវប្រើកេសឬប្រអប់ណាដែលរឹងមាំ។
- ប្រើរថយន្ត ដែលដំណើរការល្អហើយមានការថែទាំជាប្រចាំ។
- ធានាថាអ្នកបើកបរទាំងអស់ជាអ្នកដែលមានទំនុកចិត្ត។

- ធានាការធ្វើបែបបទយកទំនិញឲ្យបានលឿននៅកំពង់ផែសមុទ្រ អាកាសយានដ្ឋាន និងតាមច្រកព្រំដែន។

**ខ. នៅឃ្លាំងទុកដាក់ផលិតផល**

- កំណត់ការចេញចូលឃ្លាំង គឺអនុញ្ញាតឲ្យតែបុគ្គលិកដែលមានភារៈកិច្ចប៉ុណ្ណោះ។
- កំណត់ចំនួនសោរឃ្លាំង រក្សាបញ្ជីឈ្មោះបុគ្គលិកដែលកាន់សោរឃ្លាំង។
- រក្សាសុវត្ថិភាពដោយបិទទ្វារ និងចាក់សោរទាំងអស់។
- ចុះត្រួតពិនិត្យដោយមិនជូនដំណឹងជាមុន។
- រាប់ស្តុកឬត្រួតពិនិត្យសារពើភណ្ឌដោយឯករាជ្យ។

**គ. នៅមណ្ឌលសុខភាព**

- ចាក់សោរបន្ទប់ ឬទូ។
- ត្រូវមានសលាកបត្រឃ្លាំងសម្រាប់ផលិតផលនិមួយៗ។
- កំណត់បរិមាណអតិបរិមាសម្រាប់ការចែកចាយ។
- ត្រូវមានសម្រង់ការប្រើប្រាស់របស់អ្នកចែកចាយតាមវេជ្ជបញ្ជានិមួយៗឬប័ណ្ណចំណាយ និងរក្សាទុកវេជ្ជបញ្ជា ឬ ប័ណ្ណចំណាយ។
- ការចែកចាយ អនុញ្ញាតឲ្យតែបុគ្គលិកឃ្លាំងប៉ុណ្ណោះ។

**ឃ. ត្រួតពិនិត្យឱសថនិង ផលិតផលសុខាភិបាលដែលបានជ្រើសរើស**

ដូចមានបន្ថែមនៅក្នុងចំណុចការការពារការបាត់បង់ ត្រូវត្រួតពិនិត្យផលិតផលដែលចរាចររហ័ស (ចែកចាយឆាប់អស់) ជានិច្ចកាលផ្ទត់ផ្គង់រយៈពេលខ្លី តម្រូវការខ្ពស់របស់អតិថិជន តម្លៃថ្លៃ ជួយសង្គ្រោះជីវិត និងងាយស្រួលលាក់បាំង ឬបន្លំ ។

**មានបច្ចេកទេស ២ សម្រាប់ត្រួតពិនិត្យឱសថនិង ផលិតផលសុខាភិបាល៖**

ជ្រើសរើសឱសថនិង ផលិតផលសុខាភិបាលណាដែលគេចង់លួចឬបន្លំប្រើ (ឧ. antibiotics, narcotics, psychotropics និង antiretroviral)។

១. ពិនិត្យមើលកំណត់ត្រាសារពើភណ្ឌស្តុកបច្ចុប្បន្ន បន្ទាប់មកធ្វើសារពើភ័ណ្ឌដោយដៃ (រាប់បរិមាណជាក់ស្តែងដែលមានលើធ្នើរ) ហើយផ្ទៀងផ្ទាត់លទ្ធផល ។

២. ពិនិត្យមើលកំណត់ត្រាសារពើភណ្ឌ ដើម្បីកំណត់បរិមាណប្រើប្រាស់ក្នុងរយៈពេលមួយជាក់លាក់។ បន្ទាប់មកពិនិត្យតារាងឱសថឬបញ្ជីវេជ្ជបញ្ជា និងរាប់ចំនួនករណីព្យាបាលនៅក្នុងរយៈពេលដូចគ្នា។ បំលែងចំនួនឱសថក្នុងករណីព្យាបាលទៅជាឯកតានៃចំនួនប្រើប្រាស់ ហើយប្រៀបធៀបតួលេខនេះ ជាមួយនឹងចំនួនស្តុកដែលបានបញ្ចេញពីឃ្លាំង។ បើរកឃើញភាពខុសគ្នាត្រូវអង្កេតបន្តទៀត។

| |
|---|
| *ត្រូវធ្វើការត្រួតពិនិត្យវិធានការសុវត្ថិភាពជាប្រចាំ* |

## ៦. ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ ១ ៖ ការរក្សាទុកដាក់និងលក្ខខណ្ឌស្លាកសញ្ញា

**សីតុណ្ហភាព**

- ប្តូរពី អង្សាសេ ទៅ ហ្វារិនហៃ (C * 1.8) + 32 = F
- ប្តូរពី ហ្វារិនហៃ ទៅ អង្សាសេ (F-32)/ 1.8 = C

**លក្ខខណ្ឌស្តុកធម្មតា**

ការស្តុកនៅកន្លែងស្ងួត ឃ្លាំងត្រូវមានខ្យល់ចេញចូលបានល្អដែលមានសីតុណ្ហភាពពី ១៥ ទៅ ២៥ អង្សាសេ អាស្រ័យលើបរិយាកាសសីតុណ្ហភាពមិនឲ្យលើសពី ៣០ អង្សាសេ។

មិនត្រូវមាន៖ ក្លិនផ្សេងៗ ការចម្លងសារធាតុនិងមេរោគ និងពន្លឺចូលខ្លាំងពេក។

**ការណែនាំស្តីពីការរៀបចំទុកដាក់**

ឱសថដែលត្រូវទុកដាក់តាមលក្ខខណ្ឌកំណត់ ត្រូវមានសេចក្តីណែនាំត្រឹមត្រូវ។ បើមិនមានតម្រូវការពិសេស (ឧ. តម្រូវឲ្យរក្សាទុកនៅកន្លែងត្រជាក់ជាប្រចាំ) អាចឲ្យមានការប្រែប្រួលខ្លះតែក្នុងរយៈពេលខ្លី ឧ. ក្នុងពេលដឹកជញ្ជូនក្នុងស្រុក ។

អនុសាសន៍នៃការណែនាំក្នុងការប្រើស្លាកសញ្ញា ៖

នៅលើស្លាកត្រូវសរសេៈ

"ហាមរក្សាទុកនៅសីតុណ្ហភាពលើសពី ៣០ អង្សាសេ " គឺពី ២ អង្សាសេ ទៅ ៣០ អង្សាសេ

"ហាមរក្សាទុកនៅសីតុណ្ហភាពលើសពី ២៥ អង្សាសេ " គឺពី ២ អង្សាសេ ទៅ ២៥ អង្សាសេ

"ហាមរក្សាទុកនៅសីតុណ្ហភាពលើសពី ១៥ អង្សាសេ " គឺពី ២ អង្សាសេ ទៅ ១៥ អង្សាសេ

"ហាមរក្សាទុកនៅសីតុណ្ហភាពលើសពី ៨ អង្សាសេ " គឺពី ២ អង្សាសេ ទៅ ៨ អង្សាសេ

"ហាមរក្សាទុកនៅសីតុណ្ហភាពក្រោម ៨ អង្សាសេ " គឺពី ៨ អង្សាសេ ទៅ ២៥ អង្សាសេ

"ការពារកុំឲ្យមានសំណើម" សំណើមបរិយាកាសមិនឲ្យលើសពី៦០% ដែលជាលក្ខខណ្ឌធម្មតាក្នុងការរក្សាទុក ដាក់ ។ ត្រូវដាក់ក្នុងសម្ភារៈវេចខ្ចប់ ដែលធន់នឹងការជ្រៀតចូលនៃសំណើមបរិយាកាស។

" ការពារកុំឲ្យប៉ះពន្លឺ" ត្រូវដាក់ក្នុងសម្ភារៈវេចខ្ចប់ដែលអាចការពារកុំឲ្យពន្លឺចាំងចូល។

**ឧបសម្ព័ន្ធ ២ ៖ តារាងវាយតម្លៃដើម្បីអនុវត្តស្វ័យត្រួតពិនិត្យ**

**ក. តារាងវាយតម្លៃនៃលក្ខខណ្ឌខាងក្រៅ**

តើលោកអ្នករៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលឲ្យត្រូវនឹងលក្ខខណ្ឌនៃការទុកដាក់ដូចម្តេច? គូស (√) នៅកន្លែង "**បាទ ឬចាស** " បញ្ជាក់ថាត្រូវតាមលក្ខខណ្ឌកំណត់របស់ឃ្លាំង។ គូស (√) នៅកន្លែង "**ទេ**" បញ្ជាក់ ថាមិនត្រូវតាម លក្ខខណ្ឌកំណត់របស់ឃ្លាំង។ ពាក្យថា "**ទេ**" មានន័យថាតម្រូវឲ្យអនុវត្ត ឬធ្វើឲ្យប្រសើរឡើង។

**" បាទឬចាស "  " ទេ "**

១. □ បាទ □ទេ ឃ្លាំងមានទំហំធំគ្រប់គ្រាន់សម្រាប់រក្សាផលិតផល (ចំណុះនៃការស្តុកឱសថ និងផលិតផលសុខាភិបាលទាំងអស់មិនអោយលើសពី៦០%នៃចំណុះឃ្លាំង)

២. □ □ រចនាសម្ព័ន្ធឃ្លាំងមានស្ថានភាពល្អ មិនមានស្នាមប្រេះ រន្ធ ឬស្នាមជ្រាបទឹក។

៣. □ □ មានខ្យល់ចេញចូលគ្រប់គ្រាន់ មានកង្ហារ និងបង្អួចមានសំណាញ់ (សម្រាប់សេវាសាធារណៈ)។

៤. □ □ បង្អួចត្រូវលាបពណ៌សឬមានវាំងនន ត្រូវមានចម្រឹងសុវត្ថិភាព (សម្រាប់សេវាសាធារណៈ) ។

៥. □ □ មិនត្រូវមានសត្វចង្រៃចេញចូល ឬនៅក្នុងឃ្លាំង។

៦. □ □ ឃ្លាំងត្រូវមានរបៀបរៀបរយ ត្រូវបោសសម្អាតធ្នើរ ត្រូវជូតកម្រាលឥដ្ឋ និងជញ្ជាំងត្រូវឲ្យស្អាត។

៧. □ □ ឱសថ និងផលិតផលត្រូវស្តុកឲ្យមានរបៀបរៀបរយនៅលើធ្នើរ ឬក្នុងប្រអប់។

៨. ☐ ☐ គេសត្រូវដាក់ឲ្យផុតពីកម្រាលឥដ្ឋ គឺនៅលើកំណល់ ។

៩. ☐ ☐ ទូទឹកកកត្រូវមានស្ថានភាពល្អ មិនត្រូវមានចំណីអាហារនៅក្នុងទូទឹកកក។

**ខ. តារាងវាយតម្លៃនៃនីតិវិធីក្នុងការរៀបចំទុកដាក់**

តើលោកអ្នករៀបចំទុកដាក់ឱសថ និងផលិតផលសុខាភិបាលបានល្អដូចម្តេច? គូស (√) នៅកន្លែង "**បាទឬចាស**" បញ្ជាក់ថាត្រូវតាមលក្ខខណ្ឌកំណត់របស់ឃ្លាំង។ គូស (√) នៅកន្លែង "**ទេ**" បញ្ជាក់ថាមិនត្រូវតាមលក្ខខណ្ឌកំណត់របស់ឃ្លាំង។ ពាក្យថា "**ទេ**" មានន័យថាតម្រូវឲ្យអនុវត្ត ឬធ្វើឲ្យប្រសើរឡើង។

១. ☐ ☐ ឱសថ និងផលិតផលសុខាភិបាលត្រូវដាក់លើធ្នើរជាក្រុមៗៈ ក្រុមឱសថលាប ឬប្រើខាងក្រៅ ផឹក និងក្រុមឱសថលេប ឬប្រើខាងក្នុង និងក្រុមឱសថចាក់។

២. ☐ ☐ ឱសថគ្រាប់ កាប់ស៊ុល និងម្សៅស្ងួត (ដូចជាកញ្ចប់ ORS) ត្រូវរៀបចំទុកដាក់ក្នុងសម្ភារៈ បិទជិត និងដាក់លើធ្នើរខាងលើ។

៣. ☐ ☐ ឱសថទឹក ប៉ូម៉ាត និងឱសថចាក់ត្រូវស្តុកនៅលើធ្នើរកណ្តាល។

៤. ☐ ☐ បរិក្ខារពេទ្យដូចជា ឧបករណ៍វះកាត់ ស្រោមអនាម័យ ត្រូវដាក់នៅលើធ្នើរខាក្រោម។

៥. ☐ ☐ ឱសថ និងផលិតផលដែលតម្រូវឲ្យដាក់ប្រព័ន្ធត្រជាក់ ត្រូវរក្សាក្នុងទូទឹកកក។

៦. ☐ ☐ ឱសថញៀន និងឱសថប៉ះពាល់ផ្លូវចិត្ត ត្រូវទុកដាក់នៅកន្លែងដាច់ដោយឡែក មានចាក់សោរចំនួនពីរ។

៧. ☐ ☐ សារធាតុដែលងាយឆេះ សារធាតុកាត់ ឱសថ និងផលិតផលសុខាភិបាលដទៃទៀត ត្រូវរៀបចំទុកដាក់ឲ្យមានសុវត្ថិភាពនៅកន្លែងដាច់ដោយឡែកឆ្ងាយ ពីឃ្លាំងឱសថ។

៨. ☐ ☐ ឱសថ និងផលិតផលសុខាភិបាលត្រូវដាក់លើធ្នើរតាមលំដាប់តួរអក្សរ (ឬតាមមុខជំងឺ ឬតាមឱសថវិទ្យា ។ល។) ឬរៀបចំទុកដាក់តាមឈ្មោះហ្សេនេរិក (generic name) ។

៩. ☐ ☐ ឱសថ និងផលិតផលសុខាភិបាលត្រូវដាក់ជាក្រុមដែលងាយស្រួល ក្នុងការរាប់ចំនួន។

១០. ☐ ☐ មិនត្រូវមានឱសថ និងផលិតផលសុខាភិបាលដែលមានកាលបរិច្ឆេទផុតកំណត់ប្រើ នៅលើធ្នើរ។

១១. ☐ ☐ បានអនុវត្តតាមគោលការណ៍ជិតផុតកាលបរិច្ឆេទផុតកំណត់ប្រើ បញ្ចេញមុន (FEFO)។

១២. ☐ ☐ មិនត្រូវមានឱសថ និងផលិតផលសុខាភិបាលអន់គុណភាពនៅលើធ្នើរឡើយ។

១៣. ☐ ☐ មិនត្រូវមានឱសថ និងផលិតផលសុខាភិបាលកកស្ទះ ឬមិនប្រើនៅលើធ្នើរឡើយ។

**គ. តារាងវាយតម្លៃនៃសលាកបត្រឃ្លាំង**

តើសលាកបត្រឃ្លាំង ត្រូវបានប្រើដូចម្តេចនៅក្នុងឃ្លាំងរបស់លោក-អ្នក? គូស (√) នៅកន្លែង "**បាទឬចាស**" បញ្ជាក់ថាត្រូវតាមលក្ខខណ្ឌកំណត់របស់ឃ្លាំង។ គូស (√) នៅកន្លែង "**ទេ**" បញ្ជាក់ថាមិនត្រូវតាមលក្ខខណ្ឌកំណត់របស់ឃ្លាំង។ ពាក្យថា "**ទេ**" មានន័យថាតម្រូវឲ្យអនុវត្តឬធ្វើឲ្យប្រសើរឡើង។

១. ☐ ☐ មានសលាកបត្រឃ្លាំងសម្រាប់ឱសថ និងផលិតផលសុខាភិបាលនីមួយៗនៅក្នុងឃ្លាំង។
២. ☐ ☐ រាល់ព័ត៌មាននៅក្នុងសលាកបត្រឃ្លាំង ជាព័ត៌មានថ្មីៗ និងត្រឹមត្រូវ។
៣. ☐ ☐ សលាកបត្រឃ្លាំងត្រូវរក្សានៅលើធ្នើរ។
៤. ☐ ☐ បានកត់ត្រាលើសលាកបត្រឃ្លាំង នៅពេលមានចលនាបញ្ចេញ ឬបញ្ចូលឱសថ និងផលិតផលសុខាភិបាល ។
៥. ☐ ☐ ការរាប់ដោយដៃត្រូវធ្វើឲ្យទៀងទាត់តាមពេលកំណត់ ដូចជារាប់មួយខែមួយដង។

### ឃ. តារាងវាយតម្លៃការស្នើសុំ និងទទួលឱសថ និងផលិតផលសុខាភិបាល

តើការស្នើសុំនិងទទួលឱសថ និងផលិតផលសុខាភិបាលយ៉ាងដូចម្តេចនៅក្នុងឃ្លាំងរបស់លោក-អ្នក? គូស (√) នៅកន្លែង "**បាទឬចាស**" បញ្ជាក់ថាត្រូវតាមលក្ខខណ្ឌកំណត់របស់ឃ្លាំង។ គូស (√) នៅកន្លែង "**ទេ**" តម្រូវឲ្យអនុវត្តនិងធ្វើឲ្យប្រសើរឡើង។

១. ☐ ☐ បរិមាណស្នើសុំឡើងវិញត្រូវបានគណនាត្រឹមត្រូវទៅតាមឱសថ និផលិតផលសុខាភិបាលនីមួយៗនៅក្នុងឃ្លាំង។
២. ☐ ☐ មន្ត្រីឬបុគ្គលិកសុខាភិបាល ឬបុគ្គលិកឃ្លាំង យល់ដឹងអំពីពេលវេលាដែលត្រូវស្នើសុំឡើងវិញ ឬបញ្ជាទិញ នៅពេលតុល្យការមានបរិមាណតិចជាងបរិមាណដែលត្រូវស្នើសុំឡើងវិញ។
៣. ☐ ☐ ទម្រង់បែងចែកត្រូវបានបំពេញត្រឹមត្រូវ និងសរសេរយ៉ាងច្បាស់។
៤. ☐ ☐ ការបញ្ចេញឱសថ និងផលិតផលសុខាភិបាល ត្រូវមានអ្នកទទួលផ្ទាល់។
៥. ☐ ☐ បានពិនិត្យមើលនៅខាងក្រៅប្រអប់ឱសថ និងផលិតផលសុខាភិបាលឲ្យបានច្បាស់ នៅពេលធ្វើការបញ្ចេញឱសថ និងផលិតផលសុខាភិបាលនោះ។
៦. ☐ ☐ បានត្រួតពិនិត្យមើលកាលបរិច្ឆេទផុតកំណត់ប្រើរបស់ឱសថ និងផលិតផលសុខាភិបាលទាំងអស់។

### ង. តារាងវាយតម្លៃការរក្សាគុណភាពឱសថ និងផលិតផលសុខាភិបាល

តើគុណភាពរបស់ផលិតផល ត្រូវបានរក្សាយ៉ាងដូចម្តេចនៅក្នុងឃ្លាំងរបស់លោក-អ្នក? គូស (√) នៅកន្លែង "**បាទឬចាស**" បញ្ជាក់ថាត្រូវតាមលក្ខខណ្ឌកំណត់របស់ឃ្លាំង។ គូស (√) នៅកន្លែង "**ទេ**" តម្រូវឲ្យអនុវត្តនិងធ្វើឲ្យប្រសើរឡើង។

១. ☐ ☐ គុណភាពរបស់ឱសថ និងផលិតផលសុខាភិបាលត្រូវបានត្រួតពិនិត្យផ្នែកខាងក្រៅដូចជា៖
 ក ☐ ☐ ឱសថ និងផលិតផលដែលត្រូវរក្សាក្នុងទូទឹកកកពុំមានការវេចខ្ចប់ត្រឹមត្រូវ
 ខ. ☐ ☐ ឱសថនិងវ៉ាក់សាំងមានការប្រែពណ៌
 គ. ☐ ☐ សម្ភារៈវេចខ្ចប់បែកបាក់ និងផលិតផលខូចដោយសារធ្លាយ
 ឃ. ☐ ☐ មិនមានបិទស្លាក និងមិនបានបិទឲ្យជិត
២. ☐ ☐ បើមានឱសថ និងផលិតផលណាសង្ស័យថាខូច ត្រូវត្រួតពិនិត្យ ៖
 ក. ☐ ☐ ឱសថគ្រាប់ ឬកាប់ស៊ុលមានក្លិនមិនធម្មតា
 ខ. ☐ ☐ ឱសថគ្រាប់ ឬកាប់ស៊ុលបែកបាក់ឬខូច
 គ. ☐ ☐ ឱសថចាក់មានកករពេលចាំងពន្លឺថ្ងៃ

ឃ. ☐ ☐ មិនទទួលយកនូវផលិតផលដែលផុតកាលកំណត់ប្រើឬអន់គុណភាព

ង. ☐ ☐ បានកត់ត្រានូវភាពមិនប្រក្រតី និងបញ្ហាគុណភាពទាំងអស់

៣. ☐ ☐ គ្រប់ឱសថ និងផលិតផលដែលអន់គុណភាព និងផលិតផលដែលត្រូវបញ្ជូនត្រឡប់ ត្រូវបានរក្សាទុកនៅបន្ទប់ដោយឡែក (quarantine)

៤. ☐ ☐ បានត្រួតពិនិត្យ និងកត់ត្រាសំណើមបរិយាកាស

៥. ☐ ☐ ឱសថ និងផលិតផលដែលងាយខូចនឹងពន្លឺ ពុំត្រូវបានដាក់ឲ្យប៉ះពន្លឺ

៦. ☐ ☐ ឃ្លាំងត្រូវបានការពារមិនឲ្យពន្លឺថ្ងៃចាំងចូល

៧. ☐ ☐ បានត្រួតពិនិត្យ និងកត់ត្រាសីតុណ្ហភាពជាប្រចាំនៅក្នុងឃ្លាំង

៨. ☐ ☐ បានត្រួតពិនិត្យជាប្រចាំនូវសីតុណ្ហភាពក្នុងទូទឹកកក និងទូកក

៩. ☐ ☐ បានផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់គ្រាន់

១០ ☐ ☐ បានអនុវត្តតាមសេចក្តីណែនាំសម្រាប់រៀបចំទុកដាក់ផលិតផលរបស់រោងចក្រជានិច្ច

**ឧបសម្ព័ន្ធ ៣ ៖**

# កំណត់ហេតុស្តីពីឱសថខូចគុណភាព
# Report on defected and expired drug

មន្ទីរសុខាភិបាលខេត្ត:…………..
Provincial Health Department

ស្រុកប្រតិបត្តិ:……..…………..
Operational District

មន្ទីរពេទ្យ/មណ្ឌលសុខភាព:……..
Referral Hospital/Health Center

ចាប់ពីថ្ងៃទី……….ដល់ថ្ងៃទី……..ខែ……..ឆ្នាំ២០…….
From……………to………………………….20……

សមាសភាពចូលរួម:..…………..
Participants

1……………………………. 4…………………………
2……………………………. 5…………………………
3……………………………. 6…………………………

ឱសថរបស់កម្មវិធីជាតិ…………….
National Program Drug

វិធានការដោះស្រាយ:….....................................................................................
Solving Method:…………………………………………………………………......

| លរ.<br>**No** | កូដ<br>**Code** | ឈ្មោះឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាល<br>**Name of Drug** | ប្រភេទ<br>**Form** | កម្រិត<br>**Strength** | បរិមាណ<br>**Quantity** | ថ្លៃឯកត្តា<br>**Unit Price** | ថ្លៃសរុប<br>**Total Price** | គ្រឹះស្ថានផលិត<br>**Manufacturer** | លេខឡូត៍<br>**Lot No** | ថ្ងៃខែផុតកំណត់<br>**Expiry date** | អង្គភាពផ្គត់ផ្គង់<br>**Source** | ប័ណ្ណបញ្ចេញ លេខចុះថ្ងៃខែឆ្នាំ | ផ្សេងៗ<br>**Observation** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

សរុបទឹកប្រាក់……………………………………………………….. (សរសេរអក្សរ……………………………………………………………………….)

ថ្ងៃទី……………ខែ……………..ឆ្នាំ ២០

ប្រធានអង្គភាព　　　　ប្រធានគណនេយ្យ　　　　អ្នកធ្វើរបាយការណ៍